ក

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៤-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១១០ ស្តីពីការប្រោសព្រះរាជទាន គ្រឿង ឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ជូនអស់លោក ចំនួន ០៣ រូប	២៧៣៧
១៤-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១១៣ ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម នាយឧត្តមសេនីយ៍ផ្កាយមាស ៤ **ឈឹម ខិមយ៉ុន** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ	២៧៣៨
១៤-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១១៤ ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម **អ៊ុច គឹមអន** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា	២៧៣៩
១៤-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១១៥ ស្តីពីការបញ្ចប់មុខតំណែងឯកឧត្តម **ទ៉ាន មាន** ពីជំនួយការ ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី និង ត្រូវបានតែងតាំង ឯកឧត្តម **ឡុច ផល្លា** ជាជំនួយការ ឯកឧត្តម **ញឹក ប៊ុនឆៃ** ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ជំនួសវិញ	២៧៤០
១៤-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១១៧ ស្តីពីការតែងតាំង ឯកឧត្តម **ឡុខ ម៉េង** ជា ឧកញ៉ា	២៧៤១
១៦-៣-២០០៧	-ព្រះរាជក្រឹត្យ នស/រកត/០៣០៧/១១៨ ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហាន នៃកងយោធពលខេមរភូមិន្ទ	២៧៤២

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

២០-៣-២០០៧	-អនុក្រឹត្យលេខ ២៥ អនក្រ.បក ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ	២៧៤៤
២១-៣-២០០៧	-អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីការបង្កើតសាកលវិទ្យាល័យបាត់ដំបង	២៧៥៨

២០-៣-២០០៧	-អនុក្រឹត្យលេខ ២១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៧៦១
២០-៣-២០០៧	-អនុក្រឹត្យលេខ ២១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៧៦៣
២០-៣-២០០៧	-អនុក្រឹត្យលេខ ២១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៧៦៤
២០-៣-២០០៧	-អនុក្រឹត្យលេខ ២១៧ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២៧៦៥
២០-៣-២០០៧	-អនុក្រឹត្យលេខ ២១៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៧៦៦
២០-៣-២០០៧	-អនុក្រឹត្យលេខ ២១៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២៧៦៨
២០-៣-២០០៧	-អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២៧៦៩
២០-៣-២០០៧	-អនុក្រឹត្យលេខ ២២១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៧៧០
២០-៣-២០០៧	-អនុក្រឹត្យលេខ ២២២ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២៧៧១
២០-៣-២០០៧	-អនុក្រឹត្យលេខ ២២៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២៧៧២
២០-៣-២០០៧	-អនុក្រឹត្យលេខ ២២៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៧៧៦
២០-៣-២០០៧	-អនុក្រឹត្យលេខ ២២៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២៧៨០
២០-៣-២០០៧	-អនុក្រឹត្យលេខ ២២៦ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	២៧៩៨
២១-៣-២០០៧	-អនុក្រឹត្យលេខ ២២៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៧៩៩
២១-៣-២០០៧	-អនុក្រឹត្យលេខ ២២៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៨០០
២១-៣-២០០៧	-អនុក្រឹត្យលេខ ២២៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៨០១
២១-៣-២០០៧	-អនុក្រឹត្យលេខ ២៣០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ	២៨០២
២១-៣-២០០៧	-អនុក្រឹត្យលេខ ២៣១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៨០៣
២១-៣-២០០៧	-អនុក្រឹត្យលេខ ២៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	២៨០៤
២១-៣-២០០៧	-អនុក្រឹត្យលេខ ២៣៣ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៨០៦
២១-៣-២០០៧	-អនុក្រឹត្យលេខ ២៣៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ	២៨០៨
២១-៣-២០០៧	-អនុក្រឹត្យលេខ ២៣៥ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៨១០
២១-៣-២០០៧	-អនុក្រឹត្យលេខ ២៣៦ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៨១២
២១-៣-២០០៧	-អនុក្រឹត្យលេខ ២៣៧ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៨១៤
២១-៣-២០០៧	-អនុក្រឹត្យលេខ ២៣៨ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	២៨១៦

គ

២១-៣-២០០៧ -អនុក្រឹត្យលេខ ២៣៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨១៧

២១-៣-២០០៧ -អនុក្រឹត្យលេខ ២៤០ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលប្រចាំវិទ្យាស្ថានសុខភាពសាធារណៈ ២៨១៩

២១-៣-២០០៧ -អនុក្រឹត្យលេខ ២៤១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨២០

២១-៣-២០០៧ -អនុក្រឹត្យលេខ ២៤២ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ " កាំសាប " ២៨២១

២១-៣-២០០៧ -អនុក្រឹត្យលេខ ២៤៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២៨២៣

២១-៣-២០០៧ -អនុក្រឹត្យលេខ ២៤៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៨២៤

២១-៣-២០០៧ -អនុក្រឹត្យលេខ ២៤៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៨២៥

២_សេចក្តីសំរេច

០២-៣-២០០៧ -សេចក្តីសំរេចលេខ ១១ សសរ ស្តីពីការតែងតាំងសមាសភាព សមាជិក សមាជិកានៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារ ២៨២៦

២០-៣-២០០៧ -សេចក្តីសំរេចលេខ ១៥ សសរ ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចុះពិនិត្យទីតាំងសិក្សាស្រាវជ្រាវរ៉ែត្បូង នៅតំបន់ភ្នំគ្រប់ ក្រុងប៉ៃលិន របស់ក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD. ២៨២៨

២២-៣-២០០៧ -សេចក្តីសំរេចលេខ ១៦ សសរ ស្តីពីការបង្កើតគណៈកម្មការសំរាប់ចាត់ចែង ការសាងសង់អាគារ សាកលវិទ្យាល័យបាត់ដំបង ២៨៣១

III_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២០-៣-២០០៧ -ប្រកាសលេខ ១៨៥ សហវ.ប្រក ស្តីពីអភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង ២៨៣៤

២០-៣-២០០៧ -ប្រកាសលេខ ១៨៦ សហវ.ប្រក ស្តីពីកម្រិតសាធនភាពសំរាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ២៨៤០

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២១-៣-២០០៧ -ប្រកាសលេខ ៣៣០ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ជី តៃ សូវីង ស្រេតបង្កើតសាខារោងចក្រ " ខារអំបោះ " ដែលមានឈ្មោះថា " ជី តៃ សូវីង ស្រេត " ២៨៤៣

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៩-៣-២០០៧ -ប្រកាសលេខ ៣៨៦ ប្រក ស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ២៨៤៥

១៩-០២-២០០៧ -សេចក្តីសម្រេចលេខ០៤៨ សសរ/គ.ជ.វ.វ ស្តីពីតួនាទី ភារកិច្ចនិងរបៀបរបបការងារ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ២៨៤៦

១៩-០២-២០០៧ -សេចក្តីសម្រេចលេខ០៤៩ សសរ/គ.ជ.វ.វ ស្តីពីតួនាទី ភារកិច្ចនិងរបៀបរបបការងារ របស់ក្រុមការងារ នៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ២៨៥៥

៤_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០២២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រីម ប្រូភើធី អិលធីឌី** ២៨៦១

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទិចតូរីយ៉ា.ទ៉ាយ.អ៊ិន** ២៨៦៣

០៣-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០២៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ណា ណម ស៊ី អិន ស៊ី (ខេមបូឌា)** ២៨៦៥

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក - គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ

១- លោក គួយ ប៊ុនសន

ខ - គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ

១- លោក ជិ គេង

២- លោក មួង សំអាត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧ល.០៧០៣.១២០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៧

លេខៈ ១៣៧២ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ០១ ឆ្នាំ២០០៧
អគ្គលេខាធិការរដ្ឋាភិបាល
ស៊ុន ជិនគេន

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម នាយឧត្តមសេនីយ៍ផ្កាយមាស ៤ **ឈឹម ឱមយ៉ុន**

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៣.១២៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៧

លេខៈ ១៣៣ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ០៣ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម អ៊ុង គីមអ៊ាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ១៧៤ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ៣ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ពស.០៧០៣.១២៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៧

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១១៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានបញ្ចប់មុខតំណែងឯកឧត្ដម វ៉ាន មាន ពីជំនួយការ ឯកឧត្ដម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី ។

មាត្រា ២: ត្រូវបានតែងតាំងឯកឧត្ដម ឡុច ផល្លា ជាជំនួយការ ឯកឧត្ដម ញឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក ជំនួសឯកឧត្ដម វ៉ាន មាន ដែលត្រូវបានបញ្ចប់ពីមុខតំណែង ។

មាត្រា ៣: សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣៧.០៧០៣.១២៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៧

លេខ: ១៣០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ ៣ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ទីនភេន

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក ឡុង ម៉េង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ស.ល.០៧០៣.១២៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០៧

លេខ: ១៣៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ០៣ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន កេន

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/១១៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ ជូននាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

ក-តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី សោម ជិន អត្តលេខ ០០១០៨៩

២-ឧត្តមសេនីយ៍ត្រី អៀង ឧត្ត អត្តលេខ ០០២៣៩៦

ខ-តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក យ៉ាត ឌុច អត្តលេខ ០០៣៧៧៣

២-វរសេនីយ៍ឯក ប្រាជ្ញ សុផល អត្តលេខ ០០៤៥៨៣

៣-វរសេនីយ៍ឯក ឈឹម ទាសនា អត្តលេខ ០០៣៧៧៩

៤-វរសេនីយ៍ឯក អ៊ុន សារិន អត្តលេខ ០០៣៨៥២

៥-វរសេនីយ៍ឯក ម៉ូ សារ៉េន អត្តលេខ ០០៤១០៧

៦-វរសេនីយ៍ឯក ជួន ហេង អត្តលេខ ០០១២៨៤

៧-វរសេនីយ៍ឯក អ៊ុក សុវណ្ណសេន អត្តលេខ ០០៣៩៩៩

៨-វរសេនីយ៍ឯក យូ សារ៉ាន អត្តលេខ ០០៣៣៣៧

៩-វរសេនីយ៍ឯក លឹម ឡេង អត្តលេខ ០០៥២៧៤

១០-វរសេនីយ៍ឯក ម៉ែ សារឿន អត្តលេខ ០០៤០៩៧

១១-វរសេនីយ៍ឯក យិម គួយ អត្តលេខ ០០៣៣៨១

មាត្រា២ : សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ព/រល.០៧០៣.១២៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៧

លេខ: ១៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ២៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការគ្រប់គ្រងសហគមន៍នេសាទ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានជលផលទៅជារដ្ឋបាលជលផល
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០០ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ០៦ អនក្រ.បក លេខ ០៧ អនក្រ.បក លេខ ០៨ អនក្រ.បក លេខ ០៩ អនក្រ.បក លេខ ១០ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ១៥

អនក្រ.បក លេខ ២១ អនក្រ.បក លេខ ២២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១ អនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០០១ អនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១ និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការលុបនាទីឡូត៍នេសាទ និងការកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទក្នុងខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម រាជធានីភ្នំពេញ ខេត្តក្រចេះ ខេត្តព្រៃវែង និងខេត្តតាកែវ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.–

អនុក្រឹត្យនេះមានវិសាលភាព និងគោលដៅកំណត់អំពីវិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.–

អនុក្រឹត្យនេះមានគោលបំណង ÷

- គ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបម្រុង ទំនាបលិចទឹកក្នុងរដូវដំឡើង នាទីព្រៃលិចទឹក និងព្រៃកោងកាង និងកន្លែងនេសាទតាមឆ្នេរ
- គ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ពីធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ធ្វើឱ្យប្រជាពលរដ្ឋខ្មែរបានយល់ដឹង និងទទួលស្គាល់កាន់តែច្បាស់ឡើងនូវផលប្រយោជន៍ និងសារៈសំខាន់នៃធនធានជលផលតាមរយៈការចូលរួមគ្រប់គ្រង ប្រើប្រាស់ និងការពារធនធានជលផលដោយផ្ទាល់
- ផ្តល់ក្របខ័ណ្ឌច្បាប់សម្រាប់បង្កភាពងាយស្រួលជូនដល់ប្រជាពលរដ្ឋខ្មែរនៅតាមមូលដ្ឋានក្នុងការបង្កើតសហគមន៍នេសាទ
- លើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ ។

មាត្រា ៣.-

កន្លែងនេសាទសហគមន៍គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ៤.-

សិទ្ធិអំណាចដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទបានមកពីការបោះឆ្នោតរបស់សមាជិកសហគមន៍។

មាត្រា ៥.-

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់សម្រាប់អនុក្រឹត្យនេះត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

ជំពូកទី ២
ការបង្កើតសហគមន៍នេសាទ

មាត្រា ៦.-

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្តដើម្បីចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព។

សហគមន៍នេសាទដែលចែងក្នុងអនុក្រឹត្យនេះ ជារូបវន្តបុគ្គលមួយក្រុមមានសញ្ជាតិខ្មែរ រស់នៅក្នុង ឬក្បែរដែននេសាទ ដែលមានគំនិតផ្តួចផ្តើមដោយស្ម័គ្រចិត្តបង្កើតឡើង ដើម្បីបង្កើនជីវភាពរស់នៅរបស់ខ្លួនតាមរយៈការប្រើប្រាស់ និងកែច្នៃធនធានជលផលប្រកបដោយនិរន្តរភាព សំដៅរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ។

រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរួមសហការរៀបចំបង្កើតសហគមន៍នេសាទ។

មាត្រា ៧.-

សហគមន៍នេសាទត្រូវមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង ផែនទីកន្លែងនេសាទសហគមន៍របស់ខ្លួន និងកិច្ចព្រមព្រៀងដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

មាត្រា ៨.-

លក្ខន្តិកៈសហគមន៍នេសាទត្រូវបញ្ជាក់ពីចំណុចសំខាន់ៗដូចតទៅ ៖

- នាមករណ៍
- ទីស្នាក់ការ និងអាសយដ្ឋាន
- កម្មវត្ថុ

...

- លក្ខខណ្ឌនៃការសុំចូលជាសមាជិក
- កាតព្វកិច្ច និងសិទ្ធិរបស់សមាជិក
- លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញនៃសមាជិក
- របៀបរបបនៃការកាន់បញ្ជី និងឯកសារនានា
- សមាសភាពនៃគណៈកម្មការសហគមន៍នេសាទ
- លក្ខខណ្ឌនៃការកោះប្រជុំមហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- លក្ខខណ្ឌនៃការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- លក្ខខណ្ឌនៃការបែងចែកផលប្រយោជន៍ កម្រៃពីការធ្វើសេដ្ឋកិច្ចសមូហភាព បើសិនជាមាន
- លក្ខខណ្ឌនៃការរំលាយសហគមន៍នេសាទ
- នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ។

ជំពូកទី ៣
តួនាទី ភារកិច្ច និងសិទ្ធិរបស់សហគមន៍នេសាទ

មាត្រា ៩.—

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងចូលជាសមាជិកសហគមន៍នេសាទ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ÷

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង ។ បុគ្គលម្នាក់អាចជាសមាជិកសហគមន៍នេសាទតែមួយគត់នៃសហគមន៍ដែលខ្លួនរស់នៅ ។

មាត្រា ១០.—

តួនាទី និងភារកិច្ចរបស់សហគមន៍នេសាទ ÷

- ចូលរួមគ្រប់គ្រង អភិរក្សធនធានជលផលស្របតាមលក្ខន្តិកៈ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល
- គោរពតាមការណែនាំរបស់រដ្ឋបាលជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចូលរួមបង្កើតកន្លែងអភិរក្សក្នុងកន្លែងនេសាទសហគមន៍ ថែរក្សាការពារ និងដាំដុះព្រៃលិចទឹក និងព្រៃកោងកាងស្តារព្រែក បឹងដែលរីងរាក់ដើម្បីកែលំអប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានជលផលឡើងវិញ

- ធានាឱ្យសមាជិកទាំងអស់ក្នុងសហគមន៍នេសាទមានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពដូចមានចែងក្នុងលក្ខន្តិកៈ
- អនុវត្តលក្ខន្តិកៈសហគមន៍នេសាទ និងធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផល ដើម្បីគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព
- រក្សាទុកឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

មាត្រា ១១.–

សិទ្ធិរបស់សហគមន៍នេសាទ ÷

- ចាត់ចែងការធ្វើនេសាទរបស់សមាជិកទាំងអស់ឱ្យបានសមស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ
- សហការជាមួយរដ្ឋបាលជលផលដើម្បីបង្ក្រាបរាល់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍ ។ ក្នុងករណីបន្ទាន់ និងចាំបាច់សហគមន៍នេសាទអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតខាង ដើម្បីឃាត់ទុកវត្ថុតាងនៃបទល្មើស និងឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសរួចបញ្ជូនជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ដើម្បីដោះស្រាយបទល្មើសតាមលក្ខណៈច្បាប់
- ធ្វើទំនាក់ទំនងជាមួយសហគមន៍នេសាទនានា រូបវន្តបុគ្គល ឬនីតិបុគ្គលនានា ដើម្បីផលប្រយោជន៍របស់សហគមន៍នេសាទស្របតាមលិខិតបទដ្ឋានគតិយុត្តនានាដែលនៅជាធរមាន
- ធ្វើនេសាទ ធ្វើវារីវប្បកម្ម ប្រមូលផល លក់ ប្រើប្រាស់ និងគ្រប់គ្រងរាល់ធនធានជលផលស្របតាមកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

មាត្រា ១២.–

សហគមន៍នេសាទពុំមានសិទ្ធិ ÷

- លក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ខ្ចី បញ្ចាំ ឬផ្ទេរកន្លែងនេសាទសហគមន៍បានឡើយ ទោះតាមរូបភាពណាក៏ដោយ
- ធ្វើទំនប់ ឬធ្វើនេសាទដែលបណ្តាលឱ្យរាំងស្ទះមុខព្រែក អូរ ប្រឡាយ ឬចរាចរត្រី ។ ករណីនេះអាចធ្វើបានលុះត្រាតែមានការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់រដ្ឋបាលជលផលថ្នាក់កណ្តាលក្រោយពីបានពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ
- បែងចែកធ្វើជាកម្មសិទ្ធិឯកជននូវដីព្រៃលិចទឹក និងព្រៃកោងកាង ដីលិចទឹកព្រមទាំងកន្លែងនេសាទនៅក្នុងកន្លែងនេសាទសហគមន៍ដែលផ្តល់ឱ្យសហគមន៍នេសាទគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចុះកិច្ចព្រមព្រៀងផ្សេងៗដែលពាក់ព័ន្ធក្នុងកន្លែងនេសាទសហគមន៍ជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលនានាទោះបីក្នុងករណីស្រាវជ្រាវវិទ្យាសាស្ត្រក៏ដោយ ។

មាត្រា ១៣.–

សមាជិកសហគមន៍នេសាទមានសិទ្ធិ ៖

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះបោះឆ្នោតក្នុងរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ
- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកទាំងអស់
- លើកសំណូមពរឱ្យដាក់ចូលរបៀបវារៈនៃមហាសន្និបាតនូវបញ្ហាទាំងឡាយណាដែលមានប្រយោជន៍សម្រាប់សហគមន៍នេសាទ
- ធ្វើនេសាទជាលក្ខណៈគ្រួសារតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យជលផល និងលក្ខន្តិកៈសហគមន៍នេសាទ
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ ។

ក្នុងករណីមានសមាជិកណាម្នាក់នៃសហគមន៍នេសាទណាមួយ រារាំងមិនឱ្យសមាជិកដទៃទៀតក្នុងសហគមន៍នេសាទ ដែលខ្លួនជាសមាជិកអនុវត្តសិទ្ធិដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ឬធ្វើឱ្យមានការប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍សហគមន៍ ឬសមាជិកសហគមន៍នេសាទដទៃទៀត សមាជិករូបនោះអាចត្រូវព្យួរ ឬបណ្តេញចេញពីសហគមន៍ក្រោយពីបានការពារខ្លួនចំពោះមុខគណៈកម្មការសហគមន៍នេសាទ ។

សមាជិកសហគមន៍នេសាទ ត្រូវទទួលខុសត្រូវរៀងៗខ្លួន និងរួមគ្នាផងចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

សមាជិកថ្មីដែលសុំចូលជាសមាជិកសហគមន៍នេសាទ ត្រូវបញ្ជាក់អំពីការសុខចិត្តគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ព្រមទាំងសេចក្តីសម្រេចនានារបស់មហាសន្និបាតសហគមន៍នេសាទ ។

មាត្រា ១៤.–

អ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទអាចមានសិទ្ធិចេញ ចូល និងប្រើប្រាស់ធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ ដោយត្រូវអនុវត្តឱ្យស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ។

ជំពូកទី ៤
គណៈកម្មការសហគមន៍នេសាទ

មាត្រា ១៥.-

សហគមន៍នេសាទនីមួយៗត្រូវដឹកនាំដោយគណៈកម្មការមួយហៅថា **"គណៈកម្មការសហគមន៍នេសាទ"** ។

គណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមការបោះឆ្នោតរបស់មហាសន្និបាតដោយសម្ងាត់ សេរី ត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រភាគច្រើនដាច់ខាតពីសមាជិកសហគមន៍នេសាទដែលបានចូលរួម ។

មាត្រា ១៦.-

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ ។ បេក្ខជនដែលទទួលបានសំឡេងឆ្នោតបន្ទាប់គឺជាអនុប្រធានគណៈកម្មការសហគមន៍នេសាទ ។

រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចពាក់ព័ន្ធ ឬក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអញ្ជើញឱ្យចូលរួម សង្កេតការណ៍ ឬសម្របសម្រួលក្នុងការបោះឆ្នោត ។ លទ្ធផលនៃការបោះឆ្នោតត្រូវបានទទួលស្គាល់ជាផ្លូវការ ទោះបី អវត្តមាន នៃរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចពាក់ព័ន្ធ ឬក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ដោយ ។

មាត្រា ១៧.-

សមាជិកគណៈកម្មការសហគមន៍នេសាទមានចំនួនសេសពីប្រាំ(៥)រូប ទៅដប់មួយ(១១)រូប អាស្រ័យទៅ តាមស្ថានភាពជាក់ស្តែង និងសេចក្តីសម្រេចរបស់មហាសន្និបាត ដោយត្រូវលើកទឹកចិត្តឱ្យមានស្ត្រីភេទចូលរួមឈរឈ្មោះជា បេក្ខជនក្នុងគណៈកម្មការសហគមន៍នេសាទ ។

មាត្រា ១៨.-

ប្រជាពលរដ្ឋទាំងពីរភេទដែលមានសិទ្ធិ និងបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសជាគណៈកម្មការ សហគមន៍នេសាទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

- ជាសមាជិកនៃសហគមន៍នេសាទសាមី
- មានសញ្ជាតិខ្មែរពីកំណើត ។

មាត្រា ១៩.-

គណៈកម្មការសហគមន៍នេសាទទទួលសិទ្ធិអំណាចក្នុងកិច្ចការដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទស្រប តាមមាត្រា ១១ និងមាត្រា ១២ នៃអនុក្រឹត្យនេះ ។ គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ(៥)ឆ្នាំ ហើយផុត កំណត់ទៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

មាត្រា ២០.—

គណៈកម្មការសហគមន៍នេសាទមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- រៀបចំសេចក្តីព្រាងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ប្រតិបត្តិស្របតាមលក្ខខណ្ឌនៅក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត
- ស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីរដ្ឋបាលជលផល ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់ជំនួយផ្សេងៗក្នុងការអនុវត្តដំណើរការសហគមន៍នេសាទ
- តំណាងឱ្យសហគមន៍នេសាទក្នុងការសម្រុះសម្រួល និងដោះស្រាយទំនាស់ដែលកើតមាន
- បើកគណនី និងគ្រប់គ្រងហិរញ្ញវត្ថុសហគមន៍នេសាទ ដោយមានតម្លាភាព និងការទទួលខុសត្រូវ
- ធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍសហគមន៍នេសាទ ដោយមានការយល់ព្រមពីសមាជិកសហគមន៍នេសាទភាគច្រើនស្របទៅតាមលក្ខន្តិកៈសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ចូលរួមពិគ្រោះយោបល់ក្នុងការធ្វើបទបញ្ជានានាដែលពាក់ព័ន្ធដល់ផលប្រយោជន៍របស់សហគមន៍នេសាទ
- រាយការណ៍ និងផ្តល់ព័ត៌មានជាបន្ទាន់នូវរាល់បទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ដល់រដ្ឋបាលជលផលដែលនៅជិតបំផុត
- ធ្វើការអភិរក្ស និងការពារវារិជាតនៅក្នុងកន្លែងនេសាទសហគមន៍
- អនុវត្តតួនាទីចាំបាច់ផ្សេងៗទៀត តាមការណែនាំរបស់រដ្ឋបាលជលផល
- ធ្វើការតវ៉ាចំពោះការមិនបន្តកិច្ចព្រមព្រៀងឱ្យសហគមន៍នេសាទ ។

មាត្រា ២១.—

មានតែគណៈកម្មការសហគមន៍នេសាទទេ ដែលមានសិទ្ធិដាក់ពាក្យស្នើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ទៅខណ្ឌរដ្ឋបាលជលផលដើម្បីសុំការឯកភាព ។

គណៈកម្មការសហគមន៍នេសាទអាចស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផល ឬអ្នកដែលមានជំនាញក្នុងការគ្រប់គ្រងសហគមន៍នេសាទ ដើម្បីធ្វើការរៀបចំសេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ។

ជំពូកទី ៥

ស្ថាប័នទទួលខុសត្រូវ

មាត្រា ២២.—

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចទូទៅលើការគ្រប់គ្រងសហគមន៍នេសាទ ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើជាអាណាព្យាបាលរបស់សហគមន៍នេសាទ
- ចេញប្រកាសទទួលស្គាល់ បដិសេធ ឬរំសាយសហគមន៍នេសាទ
- ចេញប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ និងភ្ជាប់ជាមួយនូវគំរូលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយស្ថាប័ន អាជ្ញាធរ និងសហគមន៍មូលដ្ឋានពាក់ព័ន្ធ
- សម្របសម្រួលជាមួយស្ថាប័នរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀតលើការអនុវត្ត និងការអភិវឌ្ឍក្នុងការគ្រប់គ្រងសហគមន៍នេសាទ
- ធ្វើអន្តរាគមន៍ក្នុងការដោះស្រាយទំនាស់របស់សហគមន៍នេសាទ
- ជួយស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានដើម្បីឧបត្ថម្ភ និងគាំទ្រដល់សហគមន៍នេសាទ។

មាត្រា ២៣.—

រដ្ឋបាលជលផលថ្នាក់កណ្តាល មានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ធ្វើសំណើទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះបញ្ជីទទួលស្គាល់ ឬរំសាយសហគមន៍នេសាទចេញពីបញ្ជី ក្នុងករណីពិនិត្យឃើញថាសហគមន៍នេសាទមិនគោរពតាមខ្លឹមសារនៃកិច្ចព្រមព្រៀង
- ពិនិត្យ និងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ពិនិត្យ និងដោះស្រាយរាល់សំណើរបស់សហគមន៍នេសាទក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព
- ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍
- ដោះស្រាយទំនាស់វិស័យជលផលក្នុងកន្លែងនេសាទសហគមន៍
- សម្របសម្រួលក្នុងការរៀបចំសហគមន៍នេសាទ កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ លក្ខន្តិកៈសហគមន៍នេសាទ ផែនការគ្រប់គ្រងសហគមន៍នេសាទ និងការធ្វើសកម្មភាពគ្រប់គ្រងធនធានជលផលរបស់សហគមន៍នេសាទ
- ផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល និងឯកសារដែលទាក់ទងនឹងសហគមន៍នេសាទ
- អប់រំ បណ្តុះបណ្តាល ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសជំនាញសម្រាប់ការគ្រប់គ្រងដល់សហគមន៍នេសាទ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់សហគមន៍នេសាទ និងធ្វើរបាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ជួយស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានដើម្បីឧបត្ថម្ភ និងគាំទ្រដល់សហគមន៍នេសាទ។

ជំពូកទី ៦
កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

មាត្រា ២៤._

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ត្រូវភ្ជាប់មកជាមួយ ÷

- ផែនទីមាត្រដ្ឋាន ១/៥០.០០០ បញ្ជាក់ពីតំបន់ស្នើសុំបង្កើតកន្លែងនេសាទសហគមន៍ដែលមាននិយាមកាច្បាស់លាស់
- បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- សេចក្តីថ្លែងការណ៍ស្តីពីគោលបំណងនៃការបង្កើតសហគមន៍នេសាទ និងការគ្រប់គ្រងធនធានជលផល ដោយមានការអះអាងអំពីការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព
- ឯកសារពាក់ព័ន្ធផ្សេងៗទៀតក្នុងករណីចាំបាច់ ។

មាត្រា ២៥._

សេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវប្រកាសជូនដំណឹងដោយបិទផ្សាយយ៉ាងតិចសាមសិប (៣០) ថ្ងៃ នៅតាមកន្លែងសាធារណៈនានាដែលងាយមើលឃើញ នៅសាលាឃុំ សង្កាត់ ស្រុក ខណ្ឌ និងខេត្ត ក្រុង មុននឹងដាក់សេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជូនខណ្ឌរដ្ឋបាលជលផលដើម្បីពិនិត្យ និងចុះកិច្ចព្រមព្រៀង ។

ក្នុងករណីមានការជំទាស់កើតឡើងក្នុងអំឡុងពេលប្រកាសជូនដំណឹង ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរស្រុក ខណ្ឌ និងខេត្ត ក្រុង ត្រូវជួយសម្របសម្រួលដល់គណៈកម្មការសហគមន៍នេសាទដើម្បីដោះស្រាយទំនាស់ ឬកែសម្រួលសេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ តាមការស្នើឡើងដោយគណៈកម្មការសហគមន៍នេសាទ ។

នីតិវិធីនៃការរៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ២៦._

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ មានសុពលភាពមិនលើសពីរយៈពេលបី (៣) ឆ្នាំ ចាប់ពីថ្ងៃឯកភាពដោយខណ្ឌរដ្ឋបាលជលផល ។

គណៈកម្មការសហគមន៍នេសាទ ត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់ខណ្ឌរដ្ឋបាលជលផលរយៈពេលប្រាំមួយ (៦) ខែ មុនពេលកិច្ចព្រមព្រៀងផុតសុពលភាព ដើម្បីបន្តកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាថ្មី ។

ការសុំបន្តនេះ ត្រូវបានអនុញ្ញាតជូនតាមរយៈសេចក្តីជូនដំណឹងរបស់ខណ្ឌរដ្ឋបាលជលផល ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ មុនថ្ងៃផុតកំណត់នៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ។ ខណ្ឌរដ្ឋបាលជលផលបញ្ឈប់កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ឬមិនផ្តល់ការអនុញ្ញាតឱ្យបន្តប្រសិនបើខណ្ឌរដ្ឋបាលជលផល បានផ្ញើជូនគណៈកម្មការសហគមន៍

នេសាទ នូវរបាយការណ៍ស្ដីពីលទ្ធផលត្រួតពិនិត្យ និងវាយតម្លៃរបស់ថ្នាក់ផ្នែករដ្ឋបាលជលផលសាមី ដែលមានការចូលរួមជាមួយគណៈកម្មការសហគមន៍នេសាទលើដំណើរការអនុវត្តការគ្រប់គ្រងកន្លែងនេសាទសហគមន៍កន្លងមក ដោយបញ្ជាក់នូវមូលហេតុ និងកស្ដុតាងនៃការមិនគោរពកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ក្នុងករណីដែលខណ្ឌរដ្ឋបាលជលផល មិនបានផ្ដល់សេចក្ដីជូនដំណឹងចំពោះការស្នើសុំបន្តកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ មុនថ្ងៃផុតសុពលភាព កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ត្រូវបានបន្តដោយស្វ័យប្រវត្តិ ។

មាត្រា ២៧._

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍អាចបញ្ចប់មុនពេលកំណត់ ដោយផ្អែកលើលក្ខខណ្ឌណាមួយដូចខាងក្រោម÷

១- ការឯកភាពគ្នារវាងភាគីទាំងអស់ជាលាយលក្ខណ៍អក្សរ ។

២- ការព្រមព្រៀងគ្នាក្នុងគណៈកម្មការសហគមន៍នេសាទ និងមានការឯកភាពពីរភាគបី(២/៣) ពីសមាជិកសហគមន៍នេសាទ ។

៣- ការមិនអនុវត្ត ឬអនុវត្តរំលោភធ្ងន់ធ្ងរលើលក្ខខណ្ឌកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងបទប្បញ្ញត្តិនានាដែលមិនធានានិរន្តរភាពធនធានជលផល ។

៤- ការយល់ឃើញរបស់រាជរដ្ឋាភិបាលនូវគោលបំណងផ្សេងមួយទៀតដែលផ្ដល់ផលប្រយោជន៍សាធារណៈ និងសង្គមចំពោះព្រះរាជាណាចក្រកម្ពុជាច្រើនជាង ។

ក្នុងករណីដូចចំណុចទី ៤ នៃមាត្រា ២៧ នៃអនុក្រឹត្យនេះ ខណ្ឌរដ្ឋបាលជលផលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេលប្រាំមួយ(៦)ខែ មុនការបញ្ចប់ទៅឱ្យគណៈកម្មការសហគមន៍នេសាទ ដោយបញ្ជាក់ប្រាប់ពីមូលហេតុនៃការបញ្ចប់នោះ ។ ក្នុងរយៈពេលនេះ ខណ្ឌរដ្ឋបាលជលផលត្រូវធ្វើការពិភាក្សាសម្របសម្រួលជាមួយគណៈកម្មការសហគមន៍នេសាទចំពោះការបាត់បង់ផលប្រយោជន៍របស់សហគមន៍ ។

ជំពូកទី ៧
ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

មាត្រា ២៨._

បន្ទាប់ពីមានការឯកភាពលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

គណៈកម្មការសហគមន៍នេសាទអាចស្នើសុំជំនួយបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ពីរដ្ឋបាលជលផល ។

គណៈកម្មការសហគមន៍នេសាទត្រូវដាក់ស្នើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជូនទៅរដ្ឋបាលជលផល ថ្នាក់កណ្តាលតាមរយៈខណ្ឌរដ្ឋបាលជលផលសាមីដើម្បីធ្វើការពិនិត្យ និងសម្រេច។

វិធាននៃការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។

មាត្រា ២៩._

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវមានសុពលភាពស្មើនឹងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានពិនិត្យឡើងវិញដោយខណ្ឌរដ្ឋបាលជលផលរៀងរាល់ឆ្នាំ ឬមុនរយៈពេលនេះប្រសិនបើចាំបាច់ ដើម្បីរាយការណ៍ជូនរដ្ឋបាលជលផលថ្នាក់កណ្តាល។

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវមានការចូលរួមពីតំណាងគណៈកម្មការសហគមន៍នេសាទ។

រដ្ឋបាលជលផលថ្នាក់កណ្តាលអាចតម្រូវឱ្យគណៈកម្មការសហគមន៍នេសាទ ធ្វើការកែសម្រួលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឡើងវិញស្របទៅតាមលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ដើម្បីធានាដល់និរន្តរភាពនៃកន្លែងនេសាទសហគមន៍។

ជំពូកទី ៨
ប្រភពហិរញ្ញវត្ថុ

មាត្រា ៣០._

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ÷

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា
- ចំណូលស្របច្បាប់ផ្សេងៗទៀត ។

ជំពូកទី ៩
ទោសប្បញ្ញត្តិ

មាត្រា ៣១._

ជនណាដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ជំពូកទី ១០
អវសានប្បញ្ញត្តិ

មាត្រា ៣២.—

អនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣៣.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យ នេះតាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ចាន់ សារុន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ..២៥.. អនក្រ.បក ចុះថ្ងៃទី..២០..ខែ..មីនា..ឆ្នាំ ២០០៧
ស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ

កន្លែងនេសាទសហគមន៍ : សំដៅដល់ដែននេសាទរបស់រដ្ឋដែលបានព្រមព្រៀងផ្តល់សិទ្ធិជូនសហគមន៍មូលដ្ឋាន ដែលរស់នៅក្នុង ឬក្បែរដែននេសាទដើម្បីប្រើប្រាស់ជាប្រពៃណី ។

ការប្រើប្រាស់ប្រកបដោយនិរន្តរភាព : សំដៅដល់ការប្រើប្រាស់ធនធានជលផលដោយធានារក្សានូវប្រភពធនធានជលផលនោះឱ្យបានគង់វង្សសម្រាប់ជាផលប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់ ។

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ : សំដៅដល់ការព្រមព្រៀងមួយជាលាយលក្ខណ៍អក្សររវាងសហគមន៍នេសាទ និងខណ្ឌរដ្ឋបាលជលផលដែលបានផ្តល់និងធានាសិទ្ធិរបស់សហគមន៍នេសាទក្នុងកន្លែងនេសាទជាក់លាក់ណាមួយ ។

ជំនួយ : សំដៅដល់អំណោយ ឬកម្ចី ។

ទ្រព្យសម្បត្តិសាធារណៈ : សំដៅដល់ទ្រព្យដែលត្រូវរក្សាឱ្យគង់រូបតាមធម្មជាតិរបស់វា ដើម្បីទុកឱ្យអ្នករួមសង្គមប្រើប្រាស់ជាអង្វែងទៅ ។ ទ្រព្យទាំងនេះស្ថិតនៅជាប្រយោជន៍សាធារណៈមិនអាចលក់ដូរ និងគ្មានកំណត់អាជ្ញាយុកាលទេ ។

បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ : សំដៅដល់លក្ខខណ្ឌដែលបានអនុម័តដោយមហាសន្និបាតសហគមន៍នេសាទ ស្តីពីការប្រតិបត្តិផ្ទៃក្នុងរបស់សហគមន៍នេសាទ ។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ : សំដៅដល់ឯកសារដែលបានរៀបចំឡើងដោយសហគមន៍នេសាទ និងមានការឯកភាពពីរដ្ឋបាលជលផលថ្នាក់កណ្តាលដោយមានការវាយតម្លៃហេតុប៉ះពាល់សង្គម បរិស្ថាន និងបញ្ជាក់លំអិតអំពីនីតិវិធីបទបញ្ជា និងវិធានការពាក់ព័ន្ធនឹងការរៀបចំប្រើប្រាស់កន្លែងនេសាទសហគមន៍ប្រកបដោយនិរន្តរភាព ។

លក្ខន្តិកៈសហគមន៍នេសាទ : សំដៅដល់ "សេចក្តីកំណត់ដាច់ស្រេច" ដែលបានអនុម័តដោយមហាសន្និបាតសហគមន៍នេសាទ ស្របតាមគំរូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សហគមន៍នេសាទ : សំដៅដល់ក្រុមប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងភូមិមួយ ឬច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលបានយល់ព្រមសហការគ្នាចូលរួមគ្នាដោយស្ម័គ្រចិត្តក្នុងគោលបំណងចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ ប្រើប្រាស់ធនធានជលផលនៅតាមមូលដ្ឋានប្រកបដោយនិរន្តរភាព និងការពារសិទ្ធិ ព្រមទាំងជលប្រយោជន៍ប្រជាពលរដ្ឋខ្មែរស្របតាមលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៦.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតសាកលវិទ្យាល័យបាត់ដំបង

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តបាត់ដំបង

ស ម្រេ ច

មាត្រា ១..

បង្កើតសាកលវិទ្យាល័យមួយ ស្ថិតនៅតាមផ្លូវជាតិលេខ ៥ ក្នុងឃុំព្រែកព្រះស្តេច ស្រុកបាត់ដំបង ខេត្តបាត់ដំបង ដែលមានឈ្មោះថា **សាកលវិទ្យាល័យបាត់ដំបង** **"University of Battambang"** ហៅកាត់ជាភាសាខ្មែរ "ស.ប.ដ" និង ហៅកាត់ជាភាសាអង់គ្លេស "U.B.B" ។ សាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២..

សាកលវិទ្យាល័យបាត់ដំបង មានតួនាទីជាមជ្ឈមណ្ឌល បណ្តុះបណ្តាលធនធានមនុស្ស ស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស និងលើកស្ទួយអត្តសញ្ញាណជាតិ ។

មាត្រា ៣..

ចំពោះមុខសាកលវិទ្យាល័យបាត់ដំបង ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ តាមកម្មវិធីសិក្សា ដែលមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៤..

សាកលវិទ្យាល័យបាត់ដំបង មានមហាវិទ្យាល័យប្រាំ និងវិទ្យាស្ថានមួយ :

- មហាវិទ្យាល័យសិល្បៈមនុស្សសាស្ត្រ និងអប់រំ
- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- មហាវិទ្យាល័យសង្គមសាស្ត្រ និងអភិវឌ្ឍសហគមន៍
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យកសិកម្ម និងកែច្នៃអាហារ និង
- វិទ្យាស្ថានភាសាបរទេស ។

ទៅអនាគត សាកលវិទ្យាល័យបាត់ដំបង អាចបើកមហាវិទ្យាល័យ ឯកទេស ក៏ដូចជា ឬប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៥..

សាកលវិទ្យាល័យបាត់ដំបង មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និង សម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍន៍ និងការងារពាក់ព័ន្ធផ្សេងៗទៀត របស់សាកលវិទ្យាល័យ ។

មាត្រា ៦..

សាកលវិទ្យាល័យបាត់ដំបង ដឹកនាំដោយសាកលវិទ្យាធិការមួយរូប និងសាកលវិទ្យាធិការរងមួយរូប ឬច្រើនរូប ជាជំនួយការ ។

មាត្រា ៧..

តួនាទី ភារកិច្ច និង រចនាសម្ព័ន្ធគ្រប់គ្រង របស់សាកលវិទ្យាល័យបាត់ដំបង ត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ៨..

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំ មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ឱ្យបំរើការនៅក្នុងសាកលវិទ្យាល័យបាត់ដំបង ។

មាត្រា ៩..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ម៉ា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្តបាត់ដំបង
- ដូចមាត្រា ៩ -រាជកិច្ច ✓
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៤ . អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រភេទ និងជូនសប្បុរសជន ចំនួន១៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលនានា នៅក្នុងវត្តជើងឯក សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**ព្រហ្ម សាន**	បច្ច័យចំនួន ៥០.០០០ ដុល្លារ
២-លោក	**មាស ផល្លី**	គណៈកម្មការសាងសង់
៣-លោកអាចារ្យ	**សោម ម៉ុន**	ថវិកាចំនួន ៤១.០០០ ដុល្លារ
៤-លោក	**ង៉ែត ចំរើន**	ថវិកាចំនួន ២០.០០០ ដុល្លារ
៥-លោក	**ហេង ជាច**	ថវិកាចំនួន ១៨.៥០០ ដុល្លារ
៦-ឧបាសក	**ខៀវ ហ៊ីម**	ថវិកាចំនួន ១៦.០០០ ដុល្លារ
៧-លោក	**អ៊ុយ សុខន្តិត្រា**	ថវិកាចំនួន ១៥.៥០០ ដុល្លារ
៨-លោកស្រី	**ឡោក សុខ**	ថវិកាចំនួន ១៥.០០០ ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក	**សាំង ជុងអ៊ិច**	ថវិកាចំនួន ៧.០០០ ដុល្លារ
២-លោក	**ខូវ ជុនហ៊ី**	ថវិកាចំនួន ៦.៥០០ ដុល្លារ
៣-ឧបាសិកា	**ឡូន មុំ**	ថវិកាចំនួន ៦.៣០០ ដុល្លារ
៤-ឧបាសិកា	**យុង យ៉ឹន**	ថវិកាចំនួន ៦.០០០ ដុល្លារ
៥-ឧបាសក	**សេង យ៉ាន**	ថវិកាចំនួន ៥.៧០០ ដុល្លារ
៦-ឧបាសក	**យ៉ាន់ ទូ**	ថវិកាចំនួន ៥.៥០០ ដុល្លារ
៧-ឧបាសិកា	**យ៉ាំង យ៉ិង**	ថវិកាចំនួន ៥.០០០ ដុល្លារ

គ_មេដាយសំរិទ្ធស្ថាបនាជាតិ :

១-ឧបាសក	**អ៊ឹម ឈឿន**	ថវិកាចំនួន ៤.៥០០ ដុល្លារ
២-ឧបាសិកា	**អោម ដួងស៊ុនណារី**	ថវិកាចំនួន ៤.៣០០ ដុល្លារ
៣-ឧបាសក	**យិន យ៉ាន់**	ថវិកាចំនួន ៤.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ៚

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល:</u>

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៥ អនក្រ-បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសិក្សា ០១ខ្នង មាន០៥ បន្ទប់ បំពាក់ដោយគ្រឿងសង្ហារិមគ្រប់គ្រាន់ បង្គន់អនាម័យ ០២បន្ទប់ និងសមិទ្ធផលមួយចំនួនទៀត នៅសាលាបឋមសិក្សា សំព័រ ស្ថិតក្នុងឃុំ ត្រពាំងសាលាខាងលិច ស្រុកបន្ទាយមាស ខេត្ត កំពត ដូចមានរាយនាមខាងក្រោម :-

១-លោក **សួច ឆឿន** សប្បុរសជននៅក្រុងភ្នំពេញ ឧបត្ថម្ភថវិកាចំនួន ១៤.៩០០ ដុល្លារ

២-លោកស្រី **យូ លីម** សប្បុរសជននៅក្រុងភ្នំពេញ ឧបត្ថម្ភថវិកាចំនួន ១៤.៩០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣០៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេនព្រះគ្រូសីរីសត្ថាចារ្យ **ពុំ សុឃឿន** ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគបច្ច័យចូលរួមកសាង ព្រះវិហារ កុដិ សាលាឆាន់ សាលាសំណាក់ ចេតិយ៍ បណ្ណាល័យ ខ្លោងទ្វារ និងសមិទ្ធផលមួយចំនួនទៀត នៅក្នុងពុទ្ធសីមា *វត្តក្បាលកោះ* ហៅ *វត្តបឹង* ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ចំណាយអស់បច្ច័យចំនួន ២៦.៧៩១ ដុល្លារអាមេរិក ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៧
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៧-អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

ហ៊ុន សែន

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៣រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកាផ្ទាល់ខ្លួន ជួយកសាងហេដ្ឋារចនាសម្ព័ន្ធលើគ្រប់វិស័យ នៅវត្តពោធិ៍បន្ទាយជ័យ និងអគារសិក្សានៅវិទ្យាល័យ ១០ មករា ១៩៧៩ ស្ថិតក្នុងឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ព្រះភិក្ខុយសធរោ **រិត ស៊ីធីម** គង់នៅវត្តពោធិ៍បន្ទាយជ័យ ឃុំសៀមរាប ស្រុកសៀមរាប

២-លោកជំទាវ **អ៊ិន ទុនឈី** ភរិយាឯកឧត្តម **សៀង ណាំ** អ្នកតំណាងរាស្ត្រ មណ្ឌលសៀមរាប

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

-លោក **នួច សឿ និង លោកស្រី** ប្រធានក្រុមហ៊ុន ចំណតរថយន្ត ខេត្តសៀមរាប

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៨ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន២៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងអគារសិក្សា ០១ខ្នង មាន៣០បន្ទប់ នៅវិទ្យាល័យ ១០មករា ១៩៧៩ ផ្លូវលំ ០១ខ្សែ និងសមិទ្ធផលផ្សេងៗទៀត នៅវត្តពោធិបន្ទាយជ័យ ក្នុងឃុំសៀមរាប ស្រុកសៀមរាប ខេត្តសៀមរាប ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក. មេដាយមាសស្ថាបនាជាតិ :

១-លោក **ខេង សុម៉ិត** ស្នងការរងនគរបាល ខេត្តសៀមរាប ថវិកាចំនួន ២១.៥០០ ដុល្លារ

២-ឯកឧត្តម **សំ ហ៊ាង** អ្នកតំណាងរាស្ត្រ មណ្ឌលសៀមរាប និងលោកជំទាវ ថវិកាចំនួន ១១.០០០ ដុល្លារ

៣-ឯកឧត្តម **អ៊ុង អឿន** អភិបាលរង ខេត្តសៀមរាប និងលោកជំទាវ ថវិកាចំនួន ១៥.០០០ ដុល្លារ

៤-លោកវរសេនីយ៍ទោ **ឈាវ គឹមយ៉ាន់** មេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្តរតនគិរី ថវិកាចំនួន ១៥.០០០ ដុល្លារ

៥-លោក **នូ ផល្លា** អភិបាលរងខេត្តសៀមរាប និង ភរិយា ថវិកាចំនួន១៣.០០០ ដុល្លារ

៦-លោក **អ៊ុំ តូច និង ភរិយា** អាជីវករនៅខេត្តសៀមរាប ថវិកាចំនួន ១១.៥០០ ដុល្លារ

៧-លោក **ស៊ុន គង់ និង ភរិយា** សាខាស្រាបៀរសាំងមីហ្គេលនៅខេត្តសៀមរាប ថវិកាចំនួន ១១.៥០០ ដុល្លារ

៨-ឯកឧត្តម **វណ្ណ សុផាណ្ណា** ទីប្រឹក្សាសម្តេច **ជា ស៊ីម** និង លោកជំទាវ ថវិកាចំនួន ១១.៥០០ ដុល្លារ

៩-លោកអនុសេនីយ៍ឯក **ជឹម ចេន** មេបញ្ជាការរងកងអន្តរាគមន៍ នៃកងរាជអាវុធហត្ថខេត្តសៀមរាប ថវិកាចំនួន ១១.៥០០ ដុល្លារ

១០-លោក **យ៉ិន ឌី** និងលោកស្រី **អ៊ុំ អេង** ម្ចាស់សណ្ឋាគារ លី អេងទី ថវិកាចំនួន ១០.៥០០ ដុល្លារ

១១-លោក **ខាត់ តាំងសួគ៌ និង ភរិយា** សប្បុរសជននៅខេត្តសៀមរាប ថវិកាចំនួន ១០.៥០០ ដុល្លារ

១២-លោក **ហ៊ុប ម៉ៃ និងភរិយា** អាជីវករកាស៊ីផ្សារលើនៅខេត្តសៀមរាប ថវិកាចំនួន ១០.៥០០ ដុល្លារ

១៣-លោក **ម៉ុន លី** ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ស្រុកសៀមរាប ខេត្តសៀមរាប ថវិកាចំនួន ១០.៥០០ ដុល្លារ

មាត្រា ៤ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមិខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២១ ខែ ៣ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៣៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក យោគ ស៊ីថុន ឋានន្តរសក្តិ វរសេនីយ៍ទោ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាអភិបាលរង ខេត្តបាត់ដំបង ។

មាត្រា ២ : លោក **យោគ ស៊ីថុន** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ០៣ ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
  អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ២៣...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **យិន នរ៉ៃន** ឋានន្តរសក្តិ វរសេនីយ៍ឯក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាអភិបាលរង ខេត្តក្រចេះ ។

មាត្រា ២ : លោក យិន នាងហៃ ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យ លេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក ទុិត សុខ ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៤ ជាអភិបាលរងខេត្តតាកែវ ។,

មាត្រា ២ : លោក ទុិត សុខ ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ [illegible] ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៤ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៣៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាអភិបាលស្រុក នៅខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :

១- លោក គល់ ស៊ីម ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ជាអភិបាលស្រុកត្រាំកក់

២- លោក នុិច ឥរ ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ ជាអភិបាលស្រុកដូនកែវ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៣ ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤០ អនក្រ-បក

អនុក្រឹត្យ
ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល
ប្រចាំវិទ្យាស្ថានជាតិសុខភាពសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦ ស្តីពីការប្រែក្លាយវិទ្យាស្ថានជាតិសុខភាពសាធារណៈ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល ប្រចាំវិទ្យាស្ថានជាតិសុខភាពសាធារណៈ ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ម៉ម ប៊ុនហេង	រដ្ឋលេខាធិការក្រសួងសុខាភិបាល	ប្រធាន
២- ឯកឧត្តម សុខ ផេង	ឥស្សរជនមានបទពិសោធន៍ផ្នែកវិទ្យាសាស្ត្រសុខាភិបាលរបស់ក្រសួងសុខាភិបាល	សមាជិក
៣- ឯកឧត្តម ស្រ៊ុន តារា	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក

៤- លោក	អ៊ុង សំអាន	នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ	សមាជិកស្ម័យប្រវត្តិ
៥- លោក	គីម អឿន	តំណាងក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
៦- លោក	ម៉ៅ ប៊ុននិន	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧- លោក	សាជុន វឌ្ឍនៈ	តំណាងបុគ្គលិកវិទ្យាស្ថានជាតិសុខភាពសាធារណៈ	សមាជិកស្ម័យប្រវត្តិ

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ០២ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ ✓

ឆ្នាំ ទី ៧ លេខ ២២ សប្តាហ៍ ទី ៣ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៧ រាជកិច្ច ទំព័រ ២៨២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យ លេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

សម្រេច

មាត្រា ១: ត្រូវបានតែងតាំងលោកស្រី ស៊ិន្ធ វណ្ណារ៉េត ជាអគ្គនាយករង នៃក្រសួងធនធានទឹក និងឧតុនិយម ។

មាត្រា ២: រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៧៤/២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល សហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ "កាំសាប"

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យ លេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យ លេខ ៨១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ "កាំសាប"
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា ១: ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាល នៃសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ "កាំសាប" សំរាប់អាណត្តិទី ៣ ដែលមានសមាសភាពដូចខាងក្រោម :

១-	ឯកឧត្តម រស់ វណ្ណា	អគ្គនាយកសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ	ជាប្រធាន
២-	លោកស្រី មីន មាណវី	តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន	ជាសមាជិក

៣- លោក	យុយ ហៀង	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
៤- លោក	នេត មុន្នី	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ជាសមាជិក
៥- លោក	លី ផាណ្ណា	តំណាងក្រសួងពាណិជ្ជកម្ម	ជាសមាជិក
៦- លោក	ស៊ាង ប៊ុនលាង	តំណាងក្រសួងមហាផ្ទៃ	ជាសមាជិក
៧- លោក	ញាន សុគុល	តំណាងនិយោជិតសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ "កាំសាប"	ជាសមាជិក ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០០៧

សម្តេចនាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៨៣.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០២រូប ដែលមានស្នាដៃល្អនិងគុណបំណាច់ធំៗជាច្រើន ក្នុងការអភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា ដោយបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង ព្រះវិហារ និងសមិទ្ធផលនានាជាច្រើនទៀត នៅមជ្ឈមណ្ឌលវិបស្សនាធុរៈ ក្រុងកែប ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

- ឧបាសិកា ស៊ុខ អ៊ឹម សប្បុរសជន បានចំណាយធនធានផ្ទាល់ខ្លួន ចំនួន ២១១.៥០០ ដុល្លារ

ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

- លោកយាយធម្មាចារ្យ សំ គន់ សប្បុរសជន បានចំណាយធនធានផ្ទាល់ខ្លួន ចំនួន ១១២.៥០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលក្រុងកែប ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤៤ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងព្រះវិហារ និងសមិទ្ធផលនានាជាច្រើនទៀត នៅមជ្ឈមណ្ឌលវិបស្សនាធុរៈ ក្រុងកែប ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-លោក **សុខ មិន**	សប្បុរសជន	ថវិកា ចំនួន ៣៣.០០០ ដុល្លារ
២-ឧបាសក **មិន ឆាត់**	សប្បុរសជន	ថវិកា ចំនួន ៣១.៥០០ ដុល្លារ
៣-ព្រះយានិត្ថេរ **ទេវ យី**	អធិបតីពុទ្ធមណ្ឌលវិបស្សនាធុរៈកម្ពុជា	បច្ច័យចំនួន ១០.២០០ ដុល្លារ
៤-ឧបាសិកា **គង់ សំឡុត**	សប្បុរសជន	ថវិកា ចំនួន ១១.០០០ ដុល្លារ
៥-ឧបាសិកា **ខុម នាងខេង**	សប្បុរសជន	ថវិកា ចំនួន ១១.៦០០ ដុល្លារ
៦-សីលវន្ត **ម៉ុ នោង**	សប្បុរសជន	ថវិកា ចំនួន ១០.៣០០ ដុល្លារ
៧-សីលវតី **ប្រាក់ ចំនួនការ**	សប្បុរសជន	ថវិកា ចំនួន ១០.៥០០ ដុល្លារ

ខ_មេដាយសំរិទ្ធស្ថាបនាជាតិ :

១-សីលវតី **ហ៊ុល សារ៉េន**	សប្បុរសជន	ថវិកា ចំនួន ២.៥០០ ដុល្លារ
២-លោកអាចារ្យ **សុខ ឡូយ**	សប្បុរសជន	ថវិកា ចំនួន ២.៥០០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលក្រុងកែប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក ឯក មនោសែន ជាជំនួយការឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយករង ជំនួសឯកឧត្តម ឈាង កាន់ឌី ដែលត្រូវបានតម្លើងឋានៈស្មើ អគ្គនាយក។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១ សសរ

សេចក្តីសម្រេច

ស្តីពី

ការតែងតាំងសមាសភាព សមាជិក សមាជិកា

នៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

ស ម្រេ ច

ប្រការ ១ : ត្រូវបានតែងតាំងជាសមាជិកភាពនៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ មានសមាសភាពដូចខាងក្រោម :

១. លោកជំទាវ	ប៊ុន រ៉ានី ហ៊ុន សែន		ប្រធានកិត្តិយស
២. លោកជំទាវ	អ៊ឹង កន្ថាផាវី	រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី	ប្រធាន
៣. លោកជំទាវ	យូ អយ	រដ្ឋលេខាធិការក្រសួងកិច្ចការនារី	អនុប្រធានអចិន្ត្រៃយ៍
៤. ឯកឧត្តម	ហ៊ឹម ឆែម	រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	អនុប្រធាន
៥. ឯកឧត្តម	ថាច់ ផែន	រដ្ឋលេខាធិការក្រសួងព័ត៌មាន	អនុប្រធាន
៦. ឯកឧត្តម	ទេព នន្ទី	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	អនុប្រធាន

៧.	លោកជំទាវ ប្រាក់ ចន្ថា	រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិកា
៨.	លោកជំទាវ ចាន់ សុធ្លាទី	អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌	សមាជិកា
៩.	ឯកឧត្តម ឧត្តមសេនីយ៍ឯក ជុំ សម្បឿន	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ	សមាជិក
១០.	លោកជំទាវ ឈឹម ណារុទ្ធ	អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិកា
១១.	ឯកឧត្តម ឈី អឿមឡាក់	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១២.	ឯកឧត្តម ទី ចន	អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១៣.	ឯកឧត្តម ម៉ុល ម៉េងឃួរ	អនុរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	សមាជិក
១៤.	ឯកឧត្តម ម៉ូយ ម៉ុណ្ណា	អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១៥.	លោកជំទាវ គង បុរាណា	អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍	សមាជិកា
១៦.	លោកជំទាវ ស៊ី ដេហ្វឺន	អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី	សមាជិកា
១៧.	ឯកឧត្តម យិន លួត	អនុរដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា	សមាជិក
១៨.	ឯកឧត្តម ឧត្តមសេនីយ៍ឯក នេត សាវឿន	អគ្គស្នងការរងនគរបាលជាតិ	សមាជិក
១៩.	ឧត្តមសេនីយ៍ត្រី អ៊ិច សំណាង	នាយសេនាធិការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
២០.	ឯកឧត្តម កែប ជុតិមា	អភិបាលរាជធានីភ្នំពេញ	សមាជិក

ប្រការ ២ : សមាជិក សមាជិកា នៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ មានភារកិច្ចអនុវត្តការងារ ទៅតាមការតម្រង់ទិសដៅនៃអនុក្រឹត្យលេខ ៨៧ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ទទួលបានលទ្ធផលល្អប្រសើរ និងអញ្ជើញចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលជីវៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥ ស.ស.រ

សេចក្តីសម្រេច

ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីចុះពិនិត្យទីតាំងសិក្សាស្រាវជ្រាវរ៉ែត្បូង នៅតំបន់ភ្នំគ្រប់ ក្រុងប៉ៃលិន របស់ក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD.

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- យោងអនុក្រឹត្យលេខ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៃ ក.អ.ក "គ.វ.ក" នាថ្ងៃទី១៥ និងទី១៩ ខែកុម្ភៈ ឆ្នាំ២០០៧ និងចំណារសម្តេចនាយករដ្ឋមន្ត្រី ប្រធាន "ក.អ.ក" ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧

សម្រេច

ប្រការ១: បង្កើតក្រុមការអន្តរក្រសួង ដើម្បីចុះពិនិត្យទីតាំងសិក្សាស្រាវជ្រាវរ៉ែត្បូង នៅតំបន់ភ្នំគ្រប់ ក្រុងប៉ៃលិន របស់ក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD. ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម ម៉ុក មារ៉េត	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន	ប្រធាន
២- ឯកឧត្តម ស៊ុយ សែម	រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	អនុប្រធាន
៣- ឯកឧត្តម នុត ណារ៉ាង	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៤- ឯកឧត្តម សួន សិទ្ធី	អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា	សមាជិក
៥- ឯកឧត្តម ហ៊ឹង ជូរ៉ាក់ស៊ី	ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៦- ឯកឧត្តម អ៊ឹង ប៊ុណ្ណារ៉ា	អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
៧- ឯកឧត្តម មួង សៅខន	អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
៨- ឯកឧត្តម ស្រ៊ុន តារា	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៩- ឯកឧត្តម សុខ ឡេង	អគ្គនាយក នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១០- ឯកឧត្តម អ៊ិច សារូ	អភិបាលរងក្រុងប៉ៃលិន	សមាជិក
១១- លោក គិត សេង	ប្រធាននាយកដ្ឋាននៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១២- លោកស្រី ជូ សុជាន់នី	ប្រធាននាយកដ្ឋាននៃក្រសួងបរិស្ថាន	សមាជិក
១៣- លោក ឆេង គីមស៊ុន	នាយករងរដ្ឋបាលព្រៃឈើ	សមាជិក
១៤- លោក យ៉ុន ហេង	អនុប្រធាននាយកដ្ឋាន នៃ ក.អ.ក គ.វ.ក	លេខាធិការ

សមាជិកក្រុមការងារទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

ប្រការ២: ក្រុមការងារអន្តរក្រសួងនេះ មានភារកិច្ចដូចតទៅ :

- ចុះពិនិត្យសិក្សាវាយតំលៃលើស្ថានភាពប៉ះពាល់បរិស្ថាននៅតំបន់ភ្នំត្រប់ ដែលបណ្តាលមកពីសកម្មភាពសិក្សាស្រាវជ្រាវរបស់ក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD. ។
- ពិនិត្យវាយតំលៃពីគុណសម្បត្តិ និងគុណវិបត្តិ ក្នុងករណីផ្តល់គោលការណ៍អោយក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD ធ្វើការសិក្សាស្រាវជ្រាវបន្ត។
- ពិនិត្យសិក្សាលើផ្នែកពាក់ព័ន្ធគ្រប់ជ្រុងជ្រោយ សំដៅធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យសំរេចលើករណីសំណើសុំបន្តការសិក្សាស្រាវជ្រាវរ៉ែត្បូង នៅតំបន់ភ្នំត្រប់ ក្រុងប៉ៃលិន របស់ក្រុមហ៊ុន SONUBA CHAM INDUSTRIES CO.,LTD. ។

ប្រការ៣: គ្រប់សមាសភាពនៃក្រុមការងារអន្តរក្រសួង មានសិទ្ធិនាំយកទៅជាមួយនូវមន្ត្រីបច្ចេកទេសជំនាញ ដោយគ្រាន់តែមានលិខិតឧទ្ទេសនាមពីប្រធានស្ថាប័នរបស់ខ្លួនបន្ថែមប៉ុណ្ណោះ នៅពេលចុះបំពេញបេសកកម្ម។

ប្រការ៤: ក្រុមការងារអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងកញ្ចប់ថវិការបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ ។

ប្រការ៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីគ្រប់ក្រសួង-គ្រប់ប្រធានស្ថាប័ន-សាលាក្រុងប៉ៃលិន និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ប្រធាន ក អ ក
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១៦...សសរ.......

សេចក្តីសំរេច

ស្តីពី

ការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារ

សាកលវិទ្យាល័យបាត់ដំបង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតសាកលវិទ្យាល័យបាត់ដំបង
- បានឃើញសេចក្តីសំរេចលេខ ៣១ សសរ. ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យខេត្តបាត់ដំបង
- យោងតាមការចាំបាច់នៃការងារ

សំរេច

ប្រការ ១.- បង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យបាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **ស ខេង**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	ប្រធាន
២- ឯកឧត្តម **ហុក ឡង់ឌី**	អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ	អនុប្រធាន
៣- ឯកឧត្តម **ប្រាជ្ញ ច័ន្ទ**	អភិបាលខេត្តបាត់ដំបង	អនុប្រធានប្រចាំការ
៤- ឯកឧត្តម **ពិត ចំណាន**	រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
៥- ឯកឧត្តម **ម៉ុច សុជាណា**	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក

៦- ឯកឧត្តម ខុល សៀន	អគ្គស្នងការរងនគរបាលជាតិ ក្រសួងមហាផ្ទៃ	សមាជិក
៧- ឯកឧត្តម ចិន ឃន	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធាន រតនាគារជាតិ	សមាជិក
៨- ឯកឧត្តម ឌុច ម៉ារឹម	អភិបាលខេត្តកំពង់ឆ្នាំង	សមាជិក
៩- ឯកឧត្តម ឆាយ សារិត	អភិបាលខេត្តពោធិសាត់	សមាជិក
១០- ឯកឧត្តម ណាំ ធុំ	អភិបាលខេត្តកំពង់ធំ	សមាជិក
១១- ឯកឧត្តម ចត់ ឡេង	ប្រធាននាយកដ្ឋានភស្តុភារ សំភារៈ និង បច្ចេកទេស ក្រសួងមហាផ្ទៃ	សមាជិក
១២- ឯកឧត្តម អ៊ី ឈាន	អភិបាលក្រុងប៉ៃលិន	សមាជិក
១៣- ឯកឧត្តម អ៊ុយ ស៊ុម	ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង	សមាជិក
១៤- ឯកឧត្តម ចាន់ ណារិត	សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម	សមាជិក
១៥- ឯកឧត្តម មាស សារឹម	ជាទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង	សមាជិក
១៦- ឯកឧត្តម ជា អឿង	អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច ក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១៧- ឯកឧត្តម អ៊ុក វណ្ណៈ	អភិបាលរងខេត្តបាត់ដំបង	សមាជិក
១៨- លោក ម៉ក់ ង៉ុយ	អគ្គនាយករងនៃអគ្គនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
១៩- លោក ឡាយ បូរិន	ប្រធាននាយកដ្ឋានសំភារៈ និងទ្រព្យសម្បត្តិរដ្ឋ ក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
២០- លោក អ៊ុយ រី	អភិបាលស្រុកបាត់ដំបង	សមាជិក
២១- លោក យូ វីរៈ	អនុប្រធាននាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
២២- លោក ឆោរ ប្រុង	នាយកខុទ្ទកាល័យសាលាខេត្តបាត់ដំបង	សមាជិកអចិន្ត្រៃយ៍
២៣- លោក ម៉ៅ ម៉ើ	ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង	សមាជិក
២៤- លោក ខូន តេនៈ	ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបាត់ដំបង	សមាជិក
២៥- លោក គុប តាន់លាង	ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបាត់ដំបង	សមាជិក
២៦- លោក ឃេង វិឡៃ	អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តបាត់ដំបង	សមាជិក
២៧- លោក ថុក ម៉ុនះឡៃ	អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង	សមាជិក
២៨- លោកឧកញ៉ា អ៊ុក ដូរ		សមាជិក

ប្រការៈ ២.- គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

- អំពាវនាវរកជំនួយឧបត្ថម្ភជាសំភារៈ និងថវិកាពីសប្បុរជននានា សំរាប់ការសាងសង់សាកលវិទ្យាល័យ
- សិក្សា និងលើកគំរោងនៃសំណង់អាគារ និងចាត់ចែងការសាងសង់
- ចាត់ចែង គ្រប់គ្រងសំភារៈសំណង់ និងត្រួតពិនិត្យការសាងសង់

- ចាត់ចែង ត្រួតពិនិត្យសំណង់ និងការបំពាក់គ្រឿងបង្គុំនៃសំណង់ និងគ្រឿងសង្ហារឹមនានា ។

ប្រការ ៣.- អនុប្រធាន និងសមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានប្រចាំការ ។

ប្រការ ៤.- សេចក្តីសំរេចលេខ ៣១ សសរ. ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការសំរាប់ចាត់ចែងការសាងសង់អាគារសាកលវិទ្យាល័យខេត្តបាត់ដំបង ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ស ខេង

កន្លែងទទួល :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- សាលាខេត្ត ក្រុងពាក់ព័ន្ធ
- ដូចចែងក្នុងប្រការ ៥
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១៩៥.....សហវ.ប្រក.

ប្រកាស

ស្តីពី

អាជីវកម្មល្បែងហ៊ុនឆោងម៉ាប់រេ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែល ប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០១ ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨អនក្រ.បក ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និង ការកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៨៤ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ជំពូក ១ : បទប្បញ្ញត្តិទូទៅ

ប្រការ ១ : ប្រកាសនេះអនុវត្តចំពោះគ្រប់ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ ក្រុមហ៊ុនធានារ៉ាប់រងបន្ត ឬ សាខាក្រុមហ៊ុនធានារ៉ាប់រងបរទេស និងសាខាក្រុមហ៊ុនធានារ៉ាប់រងបន្តបរទេស ដែលបានទទួលការអនុញ្ញាតអោយធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតដល់ប្រភពនៃកម្មសិទ្ធិ ។

ប្រការ ២ : ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណ មិនត្រូវតែងតាំងបុគ្គលណាម្នាក់ជានាយក ឬ ជានាយកប្រតិបត្តិរបស់ក្រុមហ៊ុននោះទេ ប្រសិនបើមិនមានការឯកភាពជាលាយលក្ខណ៍អក្សរជាមុនពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

នៅក្នុងប្រកាសនេះ ពាក្យថា "នាយក" សំដៅដល់បុគ្គលដែលកាន់មុខតំណែងជា នាយក រួមទាំងបុគ្គលដែលមានអំណាចថានានុក្រមលើនាយកនោះ ។ រីឯនាយកប្រតិបត្តិសំដៅលើបុគ្គលមួយរូប ឬបុគ្គលមួយក្រុមដែលទទួលការតែងតាំងពីក្រុមប្រឹក្សាភិបាល ក្នុងការទទួលខុសត្រូវគ្រប់គ្រងអាជីវកម្ម និងអង្គភាពនោះ ។

ជំពូក ២ : លក្ខណៈវិនិច្ឆ័យ «សមស្រប»

ប្រការ ៣ : ការតែងតាំងបុគ្គលណាម្នាក់ ដើម្បីឱ្យកាន់តំណែងជានាយក នាយកប្រតិបត្តិ ឬ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ត្រូវធ្វើឡើងដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ «សមស្រប» ដូចខាងក្រោម :

ក) សុចរិតភាព សមត្ថភាព និងសុភវិនិច្ឆ័យក្នុងការបំពេញភារកិច្ច និងការទទួលខុសត្រូវលើមុខតំណែង

ខ) ការយកចិត្តទុកដាក់ក្នុងការបំពេញភារកិច្ច

គ) ការពិនិត្យលើលក្ខខណ្ឌថា តើការចូលកាន់តំណែងរបស់គាត់ អាចជាការគម្រាមដល់ផលប្រយោជន៍របស់ម្ចាស់ប័ណ្ណសន្យារ៉ាប់រង អ្នកទាមទារសំណងធានារ៉ាប់រង អតិថិជន និង ឥណទាយករបស់ក្រុមហ៊ុនធានារ៉ាប់រងនោះ ដែរឬទេ?

ប្រការ ៤ : លក្ខណៈសម្បត្តិដោយឡែកសំរាប់ នាយកដូចខាងក្រោម :

១- ប្រវត្តិនៃការសិក្សា និងបទពិសោធន៍ការងារ ដែលធានាឱ្យបុគ្គលនោះអាចបំពេញភារកិច្ចបានប្រកបដោយប្រសិទ្ធភាព ។

២- មិនធ្លាប់ធ្វើអ្វីដែលបង្ហាញនូវការសង្ស័យ លើភាពសមស្របរបស់គាត់ក្នុងការកាន់មុខតំណែងជានាយក ។

៣- ត្រូវយល់ព្រមចូលរួម ឬ បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនធានារ៉ាប់រងនោះយ៉ាងតិច ៧៥ភាគរយ ក្នុងមួយឆ្នាំ ហើយក្នុងករណីអវត្តមាន ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៤- មិនធ្លាប់ប្រើសកម្មភាព ឬការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ទៅធ្វើឱ្យខូចប្រយោជន៍ដល់ក្រុមហ៊ុនធានារ៉ាប់រងនោះ និង ធ្វើឱ្យខូចប្រយោជន៍ដល់អ្នកប្រើប្រាស់ ។

ប្រការ ៥ : លក្ខណៈសម្បត្តិដោយឡែកសំរាប់ នាយកប្រតិបត្តិ ឬ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រងដូចខាងក្រោម :

១- មានប្រវត្តិនៃការសិក្សានិងបទពិសោធន៍ការងារ ដែលធានាអោយបុគ្គលនោះអាចបំពេញតួនាទី និងការទទួលខុសត្រូវបានត្រឹមត្រូវ ។

២- មិនធ្លាប់កាន់តំណែងនៅក្នុងគណៈគ្រប់គ្រងនៃក្រុមហ៊ុនណាមួយ ដែលប្រព្រឹត្តល្មើស នឹងច្បាប់នៅពេលខ្លួនកាន់មុខតំណែង ហើយបើសិនដូចក្នុងករណីនេះ សាមីជនត្រូវបង្ហាញថា គាត់មិនបានដឹងឮ ឬមិនបានឯកភាពចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់នោះឡើយ ឬ ការ ប្រព្រឹត្តិនោះមិនស្ថិតនៅក្រោមសមត្ថកិច្ចរបស់គាត់ ។

៣- មិនធ្លាប់បានកាន់តំណែងនៅក្នុងគណៈគ្រប់គ្រងនៃក្រុមហ៊ុនណាមួយ :

ក) ដែលមិនបានទូទាត់ប្រាក់សំណង ឬបំណុល ដែលសំរេចដោយសាលក្រមរបស់តុលាការ

ខ) ដែលបានពន្យារការទូទាត់បំណុល ឬបង្កការលំបាកដល់ម្ចាស់បំណុល

គ) ដែលមានការតែងតាំងដោយអំណាចសាលក្រមរបស់តុលាការ នូវអ្នកទទួល ឬ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះ។

៤- ត្រូវមានលទ្ធភាពធ្វើការពេញម៉ោង ហើយមិនត្រូវមានមុខរបរ ឬធុរៈកិច្ចផ្សេងទៀតឡើយ លើកលែងតែជានាយកមិនប្រតិបត្តិ ឬ ជាភាគទុនិករបស់ក្រុមហ៊ុនផ្សេងទៀត។

៥- មិនមានមុខដំណែងដឹកនាំ ឬ មុខដំណែងដែលនាំអោយមានការទទួលខុសត្រូវនៅក្នុងគណៈបក្សនយោបាយណាមួយ ។

៦- មិនធ្លាប់បង្កស្ថានភាពទំនាស់ផលប្រយោជន៍ ជាមួយក្រុមហ៊ុន ទោះបីដោយខ្លួនផ្ទាល់ ឬ តាមរយៈស្វាមី ភរិយា បុត្រាបុត្រី មាតាបិតា ឬ បងប្អូនក៏ដោយ។

៧- មិនធ្លាប់ធ្វើអ្វីដែលបង្ហាញនូវការសង្ស័យលើភាពសមស្របរបស់គាត់ ក្នុងការកាន់តំណែងជានាយកប្រតិបត្តិ ឬ អ្នកគ្រប់គ្រង ឬការធ្វេសប្រហែសចំពោះក្រមសីលធម៌វិជ្ជាជីវៈ ជាពិសេស ក្នុងទំនាក់ទំនងជាមួយម្ចាស់បណ្ណសន្យារ៉ាប់រង និង អតិថិជន។

៨- មិនធ្លាប់ប្រើសកម្មភាព ឬការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល ឬ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រង ទៅធ្វើឱ្យខូចប្រយោជន៍ដល់ក្រុមហ៊ុនធានារ៉ាប់រងនោះ និង ធ្វើឱ្យ

ខូចប្រយោជន៍ដល់អ្នកប្រើប្រាស់ ។

ប្រការ ៦ : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានអំណាចឆន្ទានុសិទ្ធិពេញលេញក្នុងការវិនិច្ឆ័យកំណត់ថា តើបុគ្គលណាម្នាក់ ដែលបានបំពេញនូវលក្ខខណ្ឌខាងលើ ។

ជំពូក ៣ : កំហិតលើសមាសភាពរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុន

ប្រការ ៧ :

១- ប្រធានក្រុមប្រឹក្សាភិបាល គឺជាមុខតំណែងមិនប្រតិបត្តិ ។

២- ក្រុមប្រឹក្សាភិបាល ត្រូវមាននាយកឯករាជ្យមិនប្រតិបត្តិចំនួនពីររូបយ៉ាងតិច ។ នាយកឯករាជ្យគឺជាបុគ្គលដែលតំណាងឱ្យផលប្រយោជន៍របស់អ្នកប្រើប្រាស់ និងផលប្រយោជន៍របស់ភាគទុនិកដែលមិនមានតួនាទីគ្រប់គ្រង ។ នាយកឯករាជ្យមិនត្រូវស្ថិតក្នុងករណីដែលបានរៀបរាប់ដូចខាងក្រោមៈ

ក) កាន់កាប់ភាគហ៊ុនដោយផ្ទាល់ ឬដោយប្រយោលលើសពី ប្រាំ (៥)ភាគរយ នៅក្នុងក្រុមហ៊ុនធានារ៉ាប់រងនោះ ឬ ក្រុមហ៊ុនពាក់ព័ន្ធ ។

ខ) មានតំណែងជានាយកប្រតិបត្តិនៅក្រុមហ៊ុនធានារ៉ាប់រងនោះ ឬក្រុមហ៊ុនពាក់ព័ន្ធក្នុងរយៈពេលតិចជាង ពីរ (២)ឆ្នាំ គិតមកដល់ថ្ងៃតែងតាំង។

គ) មានសមាជិកនៅក្នុងបន្ទុកគ្រួសារ ដែលបាន និងកំពុងធ្វើជានិយោជិកនៅក្នុងក្រុមហ៊ុនធានារ៉ាប់រងនោះ ឬ ក្រុមហ៊ុនពាក់ព័ន្ធ នៅក្នុងរយៈពេលពីរ(២)ឆ្នាំកន្លងទៅ។

ឃ) ធ្លាប់បានធ្វើជាទីប្រឹក្សាឱ្យក្រុមហ៊ុនធានារ៉ាប់រងនោះ ឬ ក្រុមហ៊ុនពាក់ព័ន្ធនៅក្នុងរយៈពេល ពីរ (២)ឆ្នាំកន្លងទៅ។

ង) ធ្លាប់បានធ្វើប្រតិបត្តិការជំនួញដែលមានចំនួនទឹកប្រាក់លើសពី ២៨០ លានរៀល ជាមួយក្រុមហ៊ុនធានារ៉ាប់រងនោះ នៅក្នុងរយៈពេល ពីរ(២)ឆ្នាំកន្លងទៅ។

៣- តួនាទី និងការទទួលខុសត្រូវរបស់នាយកឯករាជ្យ មានដូចខាងក្រោម :

ក- សំរបសំរួលរាល់បញ្ហានៃដំណើរការគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រង

ខ- ចូលរួមប្រកបដោយការស្ថាបនា ក្នុងការអភិវឌ្ឍយុទ្ធសាស្ត្ររបស់ក្រុមហ៊ុននោះ

គ- ធានាមុខងារត្រួតពិនិត្យតម្លាភាពរបស់ក្រុមប្រឹក្សាភិបាល

ឃ- វាយតំលៃលើលទ្ធផលនៃការសំរេចគោលដៅរបស់ក្រុមហ៊ុនធានារ៉ាប់រង អោយបានត្រឹមត្រូវ

ជំពូក ៤ : គណៈកម្មការសវនកម្ម

ប្រការ ៨ :

១- គោលបំណងចំបងនៃគណៈកម្មការសវនកម្មគឺជួយដល់ក្រុមប្រឹក្សាភិបាលក្នុងការអនុវត្ត

ភារកិច្ច និងការទទួលខុសត្រូវ ដែលទាក់ទងនឹងភាពត្រឹមត្រូវ និង តម្លាភាពនៃការត្រួតពិនិត្យរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុ និងប្រព័ន្ធរាយការណ៍របស់ក្រុមហ៊ុន។

២- គណៈកម្មការសវនកម្ម ត្រូវអនុវត្តភារកិច្ចជាពិសេសដូចខាងក្រោម :

ក) ត្រួតពិនិត្យ និង វាយតម្លៃគុណភាពសវនកម្ម ដែលធ្វើឡើងដោយសវនករផ្ទៃក្នុង និង សវនករឯករាជ្យ ។

ខ) ធានាឱ្យមានការប្រាស្រ័យទាក់ទង និងការពិគ្រោះពិភាក្សារវាងក្រុមប្រឹក្សាភិបាល សវនករផ្ទៃក្នុង សវនករឯករាជ្យ និង គណៈគ្រប់គ្រង ។

គ) វាយតម្លៃភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពនៃការត្រួតពិនិត្យរដ្ឋបាល ប្រតិបត្តិការ និង គណនេយ្យ ហើយនិងភាពត្រឹមត្រូវនៃពត៌មានហិរញ្ញវត្ថុ ។

ប្រការ ៩ :

១- គណៈកម្មការសវនកម្មត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាលពីក្នុងចំណោមនាយកផ្សេងៗរបស់ក្រុមហ៊ុន ហើយត្រូវមានសមាជិកយ៉ាងតិចចំនួនបី(៣)រូប ដែលសមាជិកភាគច្រើនត្រូវជានាយកឯករាជ្យ ។

២- សមាជិកគណៈកម្មការសវនកម្មមិនត្រូវកាន់តំណែងប្រតិបត្តិនៅក្នុងក្រុមហ៊ុនធានារ៉ាប់រង ឬ ក្រុមហ៊ុនពាក់ព័ន្ធ និង មិនត្រូវមានទំនាក់ទំនងណាមួយ ដែលអាចធ្វើឱ្យបាត់បង់សុភវិនិច្ឆ័យឯករាជ្យក្នុងការអនុវត្តន៍មុខងាររបស់គណៈកម្មការសវនកម្ម តាមរយៈការលើកមតិយោបល់ នៅក្នុងក្រុមប្រឹក្សាភិបាល ។

៣- សមាជិកគណៈកម្មការសវនកម្ម មិនត្រូវមានការទទួលខុសត្រូវដោយផ្ទាល់ ឬដោយផ្នែកលើមុខងារគ្រប់គ្រងរបស់ក្រុមហ៊ុនធានារ៉ាប់រងឡើយ ។

៤- សមាជិកទាំងឡាយរបស់គណៈកម្មការសវនកម្ម ត្រូវបោះឆ្នោតជ្រើសរើសប្រធានក្នុងចំណោមសមាជិករបស់ខ្លួន ដែលប្រធានជាប់ឆ្នោតដាច់ខាតត្រូវតែជានាយកឯករាជ្យ និង មិនប្រតិបត្តិ ។

៥- ក្រុមប្រឹក្សាភិបាល ត្រូវពិនិត្យឡើងវិញនូវលក្ខខណ្ឌរបស់សមាជិកគណៈកម្មការសវនកម្មយ៉ាងតិចរៀងរាល់ពីរ (២)ឆ្នាំម្តង ។

ជំពូក ៥ : អវសានប្បញ្ញត្តិ

ប្រការ ១០ :

១- បុគ្គលណាដែលប្រព្រឹត្តល្មើស ឬមិនបានបំពេញតាមបទប្បញ្ញត្តិនៃប្រកាសនេះ នឹងត្រូវទទួលការផាកពិន័យជាប្រាក់ចំនួន ១០ លានរៀល ក្នុងរយៈពេលពីរ (២)សប្តាហ៍ បង់ចូលរតនាគារជាតិ តាមដីការអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ។

២- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចផ្តល់រយៈពេលសមស្របមួយ ដើម្បីឱ្យក្រុមហ៊ុន ដែលទទួលអាជ្ញាប័ណ្ណបំពេញបានតាមបទប្បញ្ញត្តិនានានៃប្រកាសនេះ បន្ទាប់ពីមានពាក្យស្នើសុំជាក់លាក់ណាមួយ ។

ប្រការ ១១ : រាល់បទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ១២ : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច "ដើម្បីចុះផ្សាយ"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ៤៥៦ ..... សហវ.ប្រក.

ប្រកាស

ស្តីពី

កម្រិតសាធនភាពសំរាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០៦១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និង ការកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៨៤ សហវ ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសំរួលការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ប្រកាសនេះអនុវត្តចំពោះគ្រប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងបន្ត ឬ សាខារបស់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ បរទេស និងសាខាក្រុមហ៊ុនធានារ៉ាប់រងបន្តបរទេស ដែលបានទទួលការអនុញ្ញាតអោយធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតដល់ប្រភពនៃកម្មសិទ្ធិ ។

ប្រការ ២ : ពាក្យ «សាធនភាព» គឺជាលទ្ធភាពរបស់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្នុងការរ៉ាប់រងនូវកាតព្វកិច្ច (បំណុល) ទាំងឡាយនៃគ្រប់កិច្ចសន្យាធានារ៉ាប់រង និងគ្រប់ពេលវេលា ។

ប្រការ ៣ : មូលដ្ឋានសម្រាប់វាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្ម(បំណុល)ត្រូវអនុវត្តតាមប្រកាសស្តីពីគោលការណ៍ណែនាំផ្នែកគណនេយ្យ សម្រាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅនៅកម្ពុជា ។

ប្រការ ៤ : ដោយយោងតាមមាត្រា ៥៦ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងទូទៅនីមួយៗ ដែលបានទទួលអាជ្ញាប័ណ្ណ ត្រូវរក្សាទុកនូវប្រាក់កំរិតសាធនភាពដូចកំណត់ខាងក្រោម :

១- ក្នុងឆ្នាំដំណើរការដំបូង ត្រូវមាន ៥០ ភាគរយ នៃដើមទុនចុះបញ្ជីតាមច្បាប់ ។

២- នៅពេលចំណូលបុព្វលាភរ៉ាប់រងសរុបដកចេញបុព្វលាភរ៉ាប់រងបន្តសរុបប្រចាំឆ្នាំមុន នៅសល់ស្មើ ឬទាបជាង ៦៦.៥០០ លានរៀល ត្រូវមាន ១៣.៣០០ លានរៀល ។

៣- នៅពេលចំណូលបុព្វលាភរ៉ាប់រងសរុប ដកចេញនូវបុព្វលាភរ៉ាប់រងបន្តសរុបប្រចាំឆ្នាំមុនមានចំនួនពី ៦៦.៥០០ លានរៀល ដល់ ៣៣២.៥០០ លានរៀល ត្រូវមាន ម្ភៃ (២០) ភាគរយ នៃចំណូលបុព្វលាភសរុបឆ្នាំមុន ។

៤- នៅពេលបុព្វលាភរ៉ាប់រងសរុបដកចេញនូវបុព្វលាភរ៉ាប់រងបន្តសរុបប្រចាំឆ្នាំមុនមានចំនួនលើសពី ៣៣២.៥០០ លានរៀល ត្រូវមាន : ៦៦.៥០០ លានរៀល បូកនឹង ១០ ភាគរយ នៃចំណែកបុព្វលាភដែលលើសពី ៣៣២.៥០០ លានរៀល ។

ប្រការ ៥ : ដោយអនុលោមតាមមាត្រា ៥៣ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង ចំនួនទឹកប្រាក់កម្រិតសាធនភាព ៥០ភាគរយ នៃដើមទុនចុះបញ្ជី ត្រូវរក្សាទុកក្នុងធនាគារពាណិជ្ជមួយដែលមានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ។

ប្រការ ៦ :

១- ដោយអនុលោមតាមមាត្រា ៦៧ នៃអនុក្រឹត្យស្តីពីការធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ត្រូវធ្វើការធានារ៉ាប់រងបន្ត ទៅក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់រដ្ឋចំនួនម្ភៃ (២០)ភាគរយ យ៉ាងតិចនៃសេវាកម្មធានារ៉ាប់រង ។

២- ដើម្បីធានាបាននូវសុវត្ថិភាពទីផ្សារ ក្រុមហ៊ុនធានារ៉ាប់រងនៅកម្ពុជា ត្រូវធ្វើការធានារ៉ាប់រងបន្ត

ជាមួយក្រុមហ៊ុនធានារ៉ាប់រងបរទេសទាំងឡាយណា ដែលមានចំណាត់ថ្នាក់បច្ចុប្បន្នអប្បបរមា BBB របស់ក្រុមហ៊ុន Standard & Poor's (S&P) ឬចំណាត់ថ្នាក់សមមូលរបស់ភ្នាក់ងារចាត់ថ្នាក់ ដែលទទួលស្គាល់ជាអន្តរជាតិ ។

ប្រការ ៧ : ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណ មិនត្រូវអនុញ្ញាតឱ្យបែងចែកភាគលាភលើប្រាក់ចំណេញទៅអោយភាគទុនិករបស់ខ្លួននោះទេ លើកលែងតែក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យឃើញថា ក្រុមហ៊ុននោះបាននិងកំពុងបំពេញកម្រិតសាធនភាពរួចហើយ ។ ក្នុងករណីនេះ ការបែងចែកភាគលាភអាចធ្វើឡើងបានតែក្នុងករណីដែលមានការឯកភាពជាលាយលក្ខណ៍អក្សរ ពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

ប្រការ ៨ : គ្រប់ក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណ ត្រូវផ្ញើជូនក្រសួង នូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍បញ្ជាក់អំពីកម្រិតសាធនភាព តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៩ : ក្រុមហ៊ុនណាដែលប្រព្រឹត្តផ្ទុយនឹងប្រការណាមួយនៃប្រកាសនេះ នឹងត្រូវទទួលការផាកពិន័យជាប្រាក់ចំនួន ១០ លានរៀល ក្នុងរយៈពេល ពីរ (២)សប្តាហ៍ បង់ចូលរតនាគារជាតិ តាមដីការអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

ប្រការ ១០ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីការកំណត់នៅក្នុងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ ១១ : ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ មីនា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច "ដើម្បីចុះផ្សាយ"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៣០ ឧ.ស.ក.ថ-ប្រក.

រាជធានីភ្នំពេញ. ថ្ងៃទី២១ ខែ មីនា ឆ្នាំ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៨៨/០៧ គ.វ.ក ចុះថ្ងៃទី១៥.០២.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ជី តៃ សូវីង ស្រេត ចុះថ្ងៃទី០៧.០២.២០០៧

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ជី តៃ សូវីង ស្រេត (GI TAI SEWING THREAD CO., LTD.) តំណាងដោយលោក TSAI, TSAO-CHE សញ្ជាតិចិន (តៃវ៉ាន់) អាយុ២៤ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 211758584 ចុះថ្ងៃទី ២២.១១.២០០៤ បង្កើតរោងចក្រ "ខារអំពោះ" ដែលមានឈ្មោះថា "ជី តៃ សូវីង ស្រេត (GI TAI SEWING THREAD)" មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៥ ភូមិស្វាយប៉ាក សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone: 855.23.211141 , Fax . 855.23.428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវរៀបចំរោងចក្រ ទៅតាមប្លង់ដែលបានតម្កល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ " ខាររំពោះ" ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៥ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ជី តៃ ស្ទីង ស្រេត ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ :..៣.[illegible] ប.ក

ប្រកាស
ស្តីពី
ការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៦/១២២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
-បានឃើញអនុក្រឹត្យ លេខ១៦អ.ន.ក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
-តាមសំណើចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០០៧ របស់លោក កាន់ វិរៈ ប្រធាន គណបក្សអំណាចប្រជាពលរដ្ឋ អក្សរកាត់ គ.អ.ប ។

សំរេច

ប្រការ១ : ត្រូវបានចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ **គណបក្សអំណាចប្រជាពលរដ្ឋ** ដែលមានទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ១៦C ផ្លូវលេខ២០០៤ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ២ : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាលនិងនគរបាល អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ និងគណបក្សអំណាចប្រជាពលរដ្ឋ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី...១៥...ខែ...មីនា...ឆ្នាំ២០០៧

ស ខេង

កន្លែងទទួល :
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
"ដើម្បីជូនជ្រាប"
-គ្រប់សាលាខេត្ត-ក្រុង
-ដូចប្រការ២
"ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ
លេខ ...០៤៨ ...../គ.ជ.វ.វ

លិខិតចូល
ថ្ងៃទី ១៩ ខែ ... ឆ្នាំ 20...

សេចក្តីសម្រេច
ស្តីពី
តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៥៥ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នាថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៦ ។

សម្រេច

ប្រការ១ .- តួនាទីរបស់ គ.ជ.វ.វ

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ) មានតួនាទីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីធានាឱ្យមានការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ប្រការ២ .- ភារកិច្ចរបស់ គ.ជ.វ.វ

គ.ជ.វ.វ មានភារកិច្ច ដូចខាងក្រោម ÷

- កំណត់ និងបន្តមុខងារ និងភារកិច្ចរបស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ (គ.ឃ.ស) និងរបស់គណៈកម្មការអន្តរក្រសួងដើម្បីតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ

- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រ និងដំណើរការសម្រាប់រយៈពេលអន្តរកាល និងការរំសាយកម្មវិធីសិលាជាបណ្តើរៗ

- រៀបចំ អនុម័ត និងអនុវត្តកម្មវិធីជាតិបឋម សម្រាប់ការអនុវត្ត ការអភិវឌ្ឍ បែបប្រជាធិបតេយ្យ នៅថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ ។

- រៀបចំ និងអនុម័ត ក្របខ័ណ្ឌអនុវត្តនីជាបឋម ដោយមានការគូសបញ្ជាក់ពីសកម្មភាព និងពេលវេលា ដោយត្រូវធ្វើតារាងកាលវិភាគឱ្យបានហើយស្រេច មុនការអនុម័តច្បាប់រៀបចំអង្គការ

- ស្រាវជ្រាវ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីការបង្កើតមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ សម្រាប់ដៃគូអភិវឌ្ឍន៍ដែលមានបំណងផ្តល់ធនធានគាំទ្រដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- ស្រាវជ្រាវ ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល អំពីជម្រើសដែលល្អបំផុតដើម្បីកៀរគរមូលនិធិអន្តរជាតិ សម្រាប់ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ស្រាវជ្រាវ និងរៀបចំកិច្ចព្រមព្រៀងក្រោមឆ័ត្រតែមួយរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាឱ្យបានការគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ជួយសម្របសម្រួល និងធានាឱ្យមានការពិគ្រោះយោបល់សមស្របនៅក្នុងចំណោម គ.ជ.វ.វ ក្រសួង និងស្ថាប័នគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធទៅនឹងការផ្ទេរមុខងារ និងធនធានទៅឱ្យក្រុមប្រឹក្សានៅថ្នាក់រដ្ឋបាលនានាក្រោមថ្នាក់ជាតិ

- បង្កើតវេទិការវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ឱ្យបានសមស្រប ដើម្បីធានាឱ្យមានកិច្ចសហប្រតិបត្តិការ និងការកៀរគរមូលនិធិ ។

ប្រការ៣ .- សិទ្ធិអំណាចរបស់ គ.ជ.វ.វ

ក្នុងការអនុវត្តកិច្ចការរបស់ខ្លួន គ.ជ.វ.វ មានសិទ្ធិអំណាច ដូចខាងក្រោម ÷

- ចេញសេចក្តីសម្រេច និងគោលការណ៍ណែនាំ ដែលស្ថិតក្រោមវិសាលភាពនៃសិទ្ធិអំណាចរបស់ខ្លួន

- ស្វែងរកការប្រឹក្សាយោបល់ក្នុងការធ្វើសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ ឬអនុក្រឹត្យនានា ដែលស្ថិតក្រោមវិសាលភាពនៃសិទ្ធិអំណាចរបស់ខ្លួន និងស្របទៅតាមនីតិវិធីដែលកំណត់

- ស្នើឱ្យក្រសួង ឬស្ថាប័នជាតិណាមួយ ផ្តល់ព័ត៌មានដែលពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិបឋម របស់រាជរដ្ឋាភិបាល

- ស្នើឱ្យក្រសួង ឬស្ថាប័នជាតិណាមួយ ប្រតិបត្តិតាមការស្នើសុំព័ត៌មានដែលធ្វើឡើងដោយ គ.ជ.វ.វ នៅក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយ

- ទទួលជំនួយបច្ចេកទេស សម្ភារ និងហិរញ្ញវត្ថុពីប្រភពជាតិ និងអន្តរជាតិនានា សម្រាប់អនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

- ជួបប្រជុំជាមួយទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ក្នុងគោលបំណងពិគ្រោះយោបល់ ផ្សព្វផ្សាយព័ត៌មាន ឬសម្រាប់គោលបំណងដទៃទៀត ដែលស្ថិតក្រោមវិសាលភាពនៃសិទ្ធិអំណាចរបស់ខ្លួន

- គ.ជ.វ.វ អាចធ្វើកិច្ចសន្យាជួលទីប្រឹក្សាជាតិ ឬអន្តរជាតិ បានតាមការចាំបាច់

- គ.ជ.វ.វ អាចចុះកិច្ចសន្យានានា រួមទាំងកិច្ចសន្យាទទួលជំនួយហិរញ្ញវត្ថុពីប្រភពជាតិ អន្តរជាតិ និងកិច្ចសន្យាជួលទីប្រឹក្សា

- គ.ជ.វ.វ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ។

ប្រការ៤ .- អំពីការទទួលខុសត្រូវរបស់ប្រធាន គ.ជ.វ.វ

- ប្រធាន គ.ជ.វ.វ ត្រូវដឹកនាំការប្រជុំរបស់គណៈកម្មាធិការ ក្នុងករណីប្រធានអវត្តមាន ប្រធានអង្គប្រជុំ ត្រូវធ្វើការផ្លាស់ប្តូរវេនរវាងអនុប្រធានទាំងពីររូបនៃគណៈកម្មាធិការ

- ក្នុងករណីប្រធាន និងអនុប្រធានទាំងពីររូបអវត្តមាន ហើយមានកូរ៉ុមគ្រប់គ្រាន់នោះ អង្គប្រជុំត្រូវជ្រើសរើស ប្រធានម្នាក់ពីក្នុងចំណោមសមាជិកធម្មតាដោយសម្លេងភាគច្រើន នៃសមាជិកដែលមានវត្តមានក្នុងកិច្ចប្រជុំនោះ

- ប្រធានគណៈកម្មាធិការ ត្រូវទទួលខុសត្រូវអំពីសកម្មភាពទូទៅរបស់គណៈកម្មាធិការ និងធានាឱ្យអង្គប្រជុំនានា របស់គណៈកម្មាធិការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព

- ប្រធានគណៈកម្មាធិការអាចធ្វើការបែងចែកភារកិច្ច និងការទទួលខុសត្រូវដល់សមាជិកគណៈកម្មាធិការក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន។

ប្រការ៥ .- កិច្ចការជាអាទិភាព

- រៀបចំ និងអនុម័តនូវតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ត្រុមការងារនៃ គ.ជ.វ.វ

- រៀបចំ និងអនុម័តល័ក្ខខ័ណ្ឌការងារសម្រាប់ការបង្កើតកម្មវិធីជាតិបឋម

- រៀបចំ និងអនុម័តក្របខ័ណ្ឌអនុវត្តជាបឋម ដែលមានកំណត់អំពីសមាសភាគបណ្តោះអាសន្ននានា ដូចជា ក្របខ័ណ្ឌពេលវេលា និងសកម្មភាពចម្បងៗនានា ដែលចាំបាច់ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ និងគោលនយោបាយរួមផ្សេងៗ

- រៀបចំ និងអនុម័តផែនការសកម្មភាព និងថវិកាឆ្លើយតបតាមតម្រូវការចាំបាច់ សម្រាប់រយៈពេលដែលនៅសេសសល់ក្នុងឆ្នាំ ២០០៦ និងសម្រាប់ឆ្នាំ ២០០៧ ទាំងមូល

- ការរៀបចំផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ ត្រូវអនុលោមទៅតាមតម្រូវការចាំបាច់ ដូចដែលបានកំណត់នៅក្នុងសេចក្តីព្រាងក្របខ័ណ្ឌអនុវត្តបឋម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រការ៦ .- អំពីកម្មវិធីជាតិបឋមរបស់រាជរដ្ឋាភិបាល

ក្នុងការរៀបចំកម្មវិធីជាតិបឋមរបស់រាជរដ្ឋាភិបាល គ.ជ.វ.វ. ត្រូវ

- អនុម័តកម្មវិធីជាតិបឋមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ

- អនុម័តល័ក្ខខ័ណ្ឌការងារសម្រាប់ការបង្កើតកម្មវិធីជាតិបឋមក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ

- រៀបចំឱ្យមានក្រុមអ្នកបង្កើតកម្មវិធីរាជរដ្ឋាភិបាល ដែលមានការចូលរួមពីសមាសភាពក្នុងរាជរដ្ឋាភិបាល និងតំណាងដៃគូអភិវឌ្ឍន៍

- រៀបចំល័ក្ខខ័ណ្ឌដោយត្រូវដាក់បញ្ចូលនូវវិសាលភាពការងារ និងកិច្ចការសម្រាប់សមាជិកម្នាក់ៗ នៃក្រុមអ្នកបង្កើតកម្មវិធីរាជរដ្ឋាភិបាល

- ការរៀបចំកម្មវិធីជាតិបឋម ត្រូវដាក់បញ្ចូលខ្លឹមសារ និងដំណើរការនានាដែលចាំបាច់ ជាអាទិ៍ ÷

  + សេចក្តីព្រាងច្បាប់រៀបចំអង្គការ រួមទាំងការធ្វើវិមជ្ឈការ និងវិសហមជ្ឈការផ្នែកសារពើពន្ធ និងហិរញ្ញវត្ថុ

  + គោលនយោបាយនានា ដែលពាក់ព័ន្ធដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

  + ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការកែតម្រូវឡើងវិញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រនេះក្នុងករណីចាំបាច់

  + ក្របខ័ណ្ឌអនុវត្ត ដែលបានកែតម្រូវឡើងវិញក្នុងករណីចាំបាច់

- តាមរយៈក្រុមការងាររបស់ខ្លួន គ.ជ.វ.វ ត្រូវផ្តល់គោលការណ៍ណែនាំ និងការដឹកនាំ ចំពោះក្រុមអ្នកបង្កើតកម្មវិធីរាជរដ្ឋាភិបាល

- ធានាការសម្របសម្រួលនានា ដើម្បីធានាដល់ការអនុវត្តផ្នែកនានា នៃកម្មវិធីជាតិបឋមដែលចាំបាច់ ។

ប្រការ៧ .- អំពីក្របខ័ណ្ឌអនុវត្តន៍បឋម

ក្នុងការរៀបចំក្របខ័ណ្ឌអនុវត្តនឹបឋម គ.ជ.វ.វ ត្រូវ ÷

- រៀបចំ និងអនុម័តក្របខ័ណ្ឌអនុវត្តបឋម ដែលមានកំណត់អំពីសមាសភាគបណ្តោះអាសន្ននានា ដូចជា ក្របខ័ណ្ឌពេលវេលា និងសកម្មភាពចម្បងៗនានា ដែលចាំបាច់ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ និងគោលនយោបាយរួមផ្សេងៗ

- ក្របខ័ណ្ឌអនុវត្តបឋម ត្រូវដាក់បញ្ចូលនូវដំណាក់កាលទាំងបួន ដូចខាងក្រោម ÷

  + **ដំណាក់កាលត្រៀម** ចាប់ផ្តើមពីឆ្នាំ២០០៦ រហូតដល់ច្បាប់រៀបចំអង្គការត្រូវបានអនុម័ត

  + **ដំណាក់កាលដំបូង** ចាប់ពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០០៩

  + **ដំណាក់កាលអន្តរកាល** ចាប់ផ្តើមពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១២ និង

  + **ដំណាក់កាលផ្លាស់ប្តូរ** ចាប់ពីឆ្នាំ ២០១៣ តទៅ ។

ប្រការ៨ .- អំពីការកៀរគរមូលនិធិ

ការកៀរគរមូលនិធិសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គ.ជ.វ.វ ត្រូវ ៖

- ផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាល អំពីជម្រើសយន្តការ ទីភ្នាក់ងារ និងការចាត់ចែងផ្សេងៗ ដែលល្អបំផុតសម្រាប់ការកៀរគរ និងគ្រប់គ្រងមូលនិធិអន្តរជាតិ សម្រាប់ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ក្នុងអនុសាសន៍ខាងលើនេះ ត្រូវដាក់បញ្ចូលនូវជម្រើសយន្តការ ទីភ្នាក់ងារ និងការចាត់ចែងផ្សេងៗ ដែលល្អបំផុតនៅមុន និងក្រោយ ការអនុម័តច្បាប់រៀបចំអង្គការ

- ត្រូវធានាឱ្យមានការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍អំពីជម្រើសយន្តការ ទីភ្នាក់ងារ និងការចាត់ចែងផ្សេងៗដែលមានលក្ខណៈល្អបំផុត ។

ប្រការ៩ .- អំពីមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ

ក្នុងការរៀបចំមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ គ.ជ.វ.វ ត្រូវ ៖

- លើកអនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីការរៀបចំឱ្យមានមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ ឱ្យបានសមស្រប ដើម្បីទាញយកធនធានគាំទ្រពីដៃគូអភិវឌ្ឍន៍

- ដាក់បញ្ចូលនូវធនធានផ្សេងៗ សម្រាប់ ៖
  + ការចំណាយផ្នែកបុគ្គលិក និងតម្រូវការខាងផ្នែកប្រតិបត្តិការរបស់អាជ្ញាធរអនុវត្តន៍ដែលនឹងត្រូវបង្កើតឡើងក្រោមច្បាប់រៀបចំអង្គការ
  + ការចំណាយរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ លើផ្នែកអភិវឌ្ឍន៍ និងតម្រូវការផ្សេងៗគ្នា
  + ការចំណាយលើផ្នែកជំនួយការបច្ចេកទេសដល់ក្រសួងផ្សេងៗ ក្នុងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការអនុលោមទៅតាមផែនការសកម្មភាព និងថវិកា ដែលពាក់ព័ន្ធរបស់អាជ្ញាធរអនុវត្តន៍

- បន្ថែមនូវថវិកាសម្រាប់គម្រោងដោយឡែករបស់ដៃគូអភិវឌ្ឍន៍ ដែលមានបំណងផ្តល់ការគាំទ្រធនធានរបស់ខ្លួន

- ធានាឱ្យមានការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍អំពីខ្លឹមសារ និងដំណើរការផ្សេងៗ សម្រាប់ការរៀបចំមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការខាងលើនេះ

- លើកអនុសាសន៍ជូនរាជរដ្ឋាភិបាល អំពីគោលនយោបាយ និងវិធីសាស្ត្រដែលល្អបំផុតសម្រាប់ការគ្រប់គ្រងមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ

- ដាក់បញ្ចូលនូវតម្រូវការ និងការធ្វើកិច្ចសន្យាជាមួយអ្នកគ្រប់គ្រងមូលនិធិ នៅក្នុងអនុសាសន៍ របស់ខ្លួន រហូតដល់ពេលដែលអាជ្ញាធរអនុវត្តន៍មានសមត្ថភាពចាត់ចែងមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ ។

ប្រការ១០ .- អំពីកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

ក្នុងការរៀបចំកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គ.ជ.វ.វ ត្រូវ ÷

- អនុម័តទម្រង់បែបបទ និងខ្លឹមសារនៃកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ស្តីពីការគាំទ្រដល់ដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ត្រូវធានាឱ្យមានកុងសង់ស៊ីសពេញលេញ និងត្រូវធ្វើឱ្យទិសដៅរបស់ដៃគូអភិវឌ្ឍន៍ស្របគ្នាទៅនឹងច្បាប់រៀបចំអង្គការ ក្របខ័ណ្ឌអនុវត្តបឋម និងកម្មវិធីជាតិបឋមរបស់រាជរដ្ឋាភិបាល ។

ប្រការ១១ .- អំពីរយៈពេលអន្តរកាល និងការរំសាយកម្មវិធីសិលាជាបណ្តើរៗ

ក្នុងរយៈពេលអន្តរកាល និងដើម្បីធានាឱ្យការរំសាយកម្មវិធីសិលាជាបណ្តើរៗ ប្រព្រឹត្តទៅមានភាពរលូន គ.ជ.វ.វ ត្រូវ ÷

- អនុម័ត និងធានាលើការអនុវត្តយុទ្ធសាស្ត្រ និងដំណើរការសម្រាប់រយៈពេលអន្តរកាល ការធ្វើសមាហរណកម្មការ គ្រប់គ្រង និងការរំសាយកម្មវិធីសិលា និងផ្នែកផ្សេងៗនៃកម្មវិធីនេះជាបណ្តើរៗ រួមទាំងការចាត់ចែងឱ្យបានសមស្របចំពោះប្រព័ន្ធឧបត្ថម្ភបៀវត្សផង

- យុទ្ធសាស្ត្រ និងដំណើរការនៃរយៈពេលអន្តរកាល និងការរំសាយកម្មវិធីសិលាជាបណ្តើរៗ ត្រូវតែជាផ្នែករួមទាំងមូលនៃកម្មវិធីជាតិបឋមរបស់រាជរដ្ឋាភិបាល

- យុទ្ធសាស្ត្រ និងដំណើរការខាងលើនេះ ត្រូវបញ្ចូលនូវយន្តការផ្សេងៗ សម្រាប់ការត្រួតពិនិត្យឡើងវិញឱ្យបានទៀងទាត់ ដើម្បីធានាលើភាពបត់បែន និងការប្រែប្រួលដែលចាំបាច់ ។

ប្រការ១២ .- អំពីកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

គ.ជ.វ.វ ត្រូវធានាឱ្យមានការសម្របសម្រួល និងពិគ្រោះយោបល់ត្រឹមត្រូវ និងគ្រប់គ្រាន់រវាង គ.ជ.វ.វ ជាមួយក្រសួង ស្ថាប័នផ្សេងៗ នៅថ្នាក់ជាតិ និងថ្នាក់រដ្ឋបាលនៅក្រោមជាតិ ។

ប្រការ១៣ .- អំពីទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាល

ដើម្បីធានាឱ្យមានការចូលរួម និងមានកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ពីសំណាក់ទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាល គ.ជ.វ.វ ត្រូវ ÷

- ធានាឱ្យមានវេទិកាសមស្រប សម្រាប់ការពិគ្រោះយោបល់ ការធ្វើទំនាក់ទំនង ការសម្របសម្រួលកិច្ចសហប្រតិបត្តិការ និងការកៀរគរមូលនិធិរវាងរាជរដ្ឋាភិបាល និងទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាលនានា

- ធានាថារាល់សកម្មភាព និងកម្មវិធីរបស់ទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាលនានា គឺត្រូវគ្នា និងស្របគ្នាទៅនឹងក្របខ័ណ្ឌអនុវត្តជាបឋម និងកម្មវិធីរាជរដ្ឋាភិបាលជាបឋម ។

ប្រការ១៤ .- អំពីអនុគណៈកម្មការរបស់ គ.ជ.វ.វ

- គ.ជ.វ.វ អាចបង្កើតអនុគណៈកម្មការនានា ដើម្បីធ្វើជាជំនួយការឱ្យខ្លួនតាមការចាំបាច់
- គ.ជ.វ.វ ត្រូវសម្រេចអំពីសមាសភាព មុខងារ និងនីតិវិធីការងាររបស់អនុគណៈកម្មការនីមួយៗ
- គ.ជ.វ.វ អាចបញ្ចូលតំណាងពីក្រសួង ឬ ស្ថាប័ននៅថ្នាក់ជាតិណាមួយឱ្យចូលរួមក្នុងអនុគណៈកម្មការតាមការចាំបាច់
- គ.ជ.វ.វ ត្រូវដាក់បញ្ចូលសមាជិកនៃត្រុមការងាររបស់ គ.ជ.វ.វ យ៉ាងហោចណាស់ឱ្យបានមួយរូបទៅក្នុងអនុគណៈកម្មការនីមួយៗ
- គ.ជ.វ.វអាចតែងតាំងមន្ត្រីណាម្នាក់ដែលមានជំនាញច្បាស់លាស់ ឱ្យធ្វើជាសមាជិកអនុគណៈកម្មការណាមួយបានក្នុងករណីចាំបាច់ ។

ប្រការ១៥ .- អំពីការប្រជុំរបស់ គ.ជ.វ.វ

- គ.ជ.វ.វ ត្រូវជួបប្រជុំជាសាមញ្ញរៀងរាល់ពីរខែម្តង
- គ.ជ.វ.វ អាចធ្វើការប្រជុំវិសាមញ្ញតាមការចាំបាច់
- ការប្រជុំវិសាមញ្ញនេះអាចធ្វើទៅបាន លុះត្រាតែមានការស្នើសុំរបស់ប្រធាន គ.ជ.វ.វ និងសមាជិក គ.ជ.វ.វ ពីររូបបន្ថែមទៀត ។

ប្រការ១៦ .- អំពីកូរ៉ុមរបស់ គ.ជ.វ.វ

- ការប្រជុំរបស់ គ.ជ.វ.វ អាចយកជាការបានលុះត្រាតែមានវត្តមាននៃសមាជិក គ.ជ.វ.វ លើសពីពាក់កណ្តាលឡើងទៅបានចូលរួម
- សមាជិក គ.ជ.វ.វ មួយរូប អាចតែងតាំងអ្នកតំណាងមួយរូបឱ្យធ្វើជាតំណាងរបស់ខ្លួននៅក្នុងកិច្ចប្រជុំណាមួយបាន ប្រសិនបើអ្នកតំណាងរូបនោះជាសមាជិករបស់រាជរដ្ឋាភិបាល
- តំណាងខាងលើនេះត្រូវមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេច ក្នុងនាមសមាជិករូបនោះ
- តំណាងនៃសមាជិក គ.ជ.វ.វ អាចរាប់ថាជាផ្នែកមួយ នៃកូរ៉ុមសម្រាប់ការប្រជុំណាមួយរបស់ គ.ជ.វ.វ ។

ប្រការ១៧ .- អំពីការអញ្ជើញឱ្យចូលរួមប្រជុំរបស់ គ.ជ.វ.វ

- គ.ជ.វ.វ អាចអញ្ជើញរដ្ឋមន្ត្រី នៃក្រសួងផ្សេងទៀត ឱ្យចូលរួមក្នុងការប្រជុំណាមួយរបស់ខ្លួនបានតាមការចាំបាច់
- គ.ជ.វ.វ អាចអញ្ជើញបុគ្គលផ្សេងទៀត ឱ្យចូលរួមក្នុងការប្រជុំរបស់ខ្លួនបានតាមការចាំបាច់ ។

ប្រការ១៨ .- អំពីសេចក្តីសម្រេចរបស់ គ.ជ.វ.វ

គ.ជ.វ.វ ត្រូវធ្វើសេចក្តីសម្រេច លើមូលដ្ឋាននៃការព្រមព្រៀងគ្នា កុងសង់ស៊ុស ។

ប្រការ១៩ .- អំពីរបៀបវារៈនៃការប្រជុំរបស់ គ.ជ.វ.វ

- លេខាធិការដ្ឋានរបស់ គ.ជ.វ.វ ត្រូវរៀបចំ និងចែកជូនសេចក្តីព្រាងរបៀបវារៈ ឱ្យបានមុនការប្រជុំ

សាមញ្ញ និងការប្រជុំវិសាមញ្ញទាំងអស់របស់ គ.ជ.វ.វ

- សេចក្តីព្រាងរបៀបវារៈសម្រាប់ការប្រជុំសាមញ្ញ ត្រូវចែកជូនដល់សមាជិក គ.ជ.វ.វ គ្រប់រូប យ៉ាងហោចណាស់ឱ្យបាន៩៦ម៉ោង មុនការប្រជុំសាមញ្ញ

- សេចក្តីព្រាងរបៀបវារៈសម្រាប់ការប្រជុំវិសាមញ្ញ ត្រូវចែកជូនដល់សមាជិក គ.ជ.វ.វ គ្រប់រូប យ៉ាងហោចណាស់ឱ្យបាន៤៨ម៉ោង មុនការប្រជុំវិសាមញ្ញ

- គ.ជ.វ.វ ត្រូវត្រួតពិនិត្យឡើងវិញនូវសេចក្តីព្រាងរបៀបវារៈ នៅមុនពេលចាប់ផ្តើមការប្រជុំនីមួយៗ ដើម្បីធ្វើវិសោធនកម្ម ឬអនុម័ត ។

ប្រការ២០ .- អំពីកំណត់ហេតុនៃការប្រជុំរបស់ គ.ជ.វ.វ

- ការប្រជុំសាមញ្ញ និងការប្រជុំវិសាមញ្ញរបស់ គ.ជ.វ.វ ត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ

- លេខាធិការដ្ឋាន គ.ជ.វ.វ ត្រូវទទួលខុសត្រូវធ្វើកំណត់ហេតុប្រជុំសាមញ្ញ និងប្រជុំវិសាមញ្ញទាំងអស់របស់ គ.ជ.វ.វ

- កំណត់ហេតុប្រជុំរបស់ គ.ជ.វ.វ ទាំងអស់ត្រូវចែកជូនសមាជិក គ.ជ.វ.វ គ្រប់រូបមិនឱ្យហួសពីការប្រជុំបន្ទាប់របស់ គ.ជ.វ.វ ដើម្បីអនុម័ត ។

ប្រការ២១ .- អំពីក្រុមការងាររបស់ គ.ជ.វ.វ

- គ.ជ.វ.វ ត្រូវស្នើឱ្យមានអនុក្រឹត្យមួយ ដើម្បីបង្កើតក្រុមការងារ គ.ជ.វ.វ

- គ.ជ.វ.វ ត្រូវសម្រេចអំពី តួនាទី ភារកិច្ច និងនីតិវិធីការងាររបស់ក្រុមការងារ គ.ជ.វ.វ

- ក្រុមការងាររបស់ គ.ជ.វ.វ មានភារកិច្ចទូទៅក្នុងការជួយ គ.ជ.វ.វ ដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ គ.ជ.វ.វ ។

ប្រការ២២ .- អំពីលេខាធិការដ្ឋានរបស់ គ.ជ.វ.វ

- លេខាធិការដ្ឋានរបស់ គ.ជ.វ.វ គឺជាអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ

- លេខាធិការដ្ឋានរបស់ គ.ជ.វ.វ គឺជាជំនួយការរបស់ គ.ជ.វ.វ និងក្រុមការងារ គ.ជ.វ.វ

- លេខាធិការដ្ឋានរបស់ គ.ជ.វ.វ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម ÷

  + រៀបចំ និងចាត់ចែងគ្រប់ការងារចាំបាច់ទាំងអស់ សម្រាប់ការប្រជុំរបស់ គ.ជ.វ.វ រួមទាំងការកំណត់កាលបរិច្ឆេទ ការរៀបចំទីកន្លែង និងការទំនាក់ទំនងជាមួយសមាជិក

  + ចាត់ចែងឱ្យមានការចែកជូនសេចក្តីព្រាងរបៀបវារៈ កំណត់ហេតុប្រជុំ និងឯកសារផ្សេងៗទៀតសម្រាប់ការប្រជុំ

  + រៀបចំ និងចាត់ចែងគ្រប់ការងារចាំបាច់ទាំងអស់ សម្រាប់ការប្រជុំផ្សេងៗទៀតដែលនឹងរៀបចំឡើងដោយ គ.ជ.វ.វ ឬ ដោយក្រុមការងារនៃ គ.ជ.វ.វ

+ ផ្តល់សេវាលេខាធិការជូន គ.ជ.វ.វ រួមទាំងការធ្វើកំណត់ហេតុប្រជុំ នៅពេលមានការប្រជុំរបស់ គ.ជ.វ.វ
+ ផ្តល់សេវាលេខាធិការជូនក្រុមការងារ
+ រៀបចំកិច្ចសន្យាដែលសមស្រប និងចាំបាច់ តាមការស្នើសុំរបស់ក្រុមការងារ ឬ គ.ជ.វ.វ
+ អនុវត្តតាមការណែនាំរបស់ គ.ជ.វ.វ និងក្រុមការងារ
+ ផ្តល់ជំនួយ និងសេវាផ្សេងៗទៀត តាមការស្នើសុំរបស់ គ.ជ.វ.វ ឬ ក្រុមការងារនៃ គ.ជ.វ.វ
+ ត្រូវរាយការណ៍ជូន គ.ជ.វ.វ និងក្រុមការងារឱ្យបានទៀងទាត់ ។

ប្រការ២៣ .- ការធ្វើវិសោធនកម្មនៅលើ តួនាទី ភារកិច្ច និងរបៀបរបបការងារ របស់ គ.ជ.វ.វ

- តួនាទី ភារកិច្ច និងរបៀបរបបធ្វើការនេះ អាចធ្វើវិសោធនកម្មបានដោយគណៈកម្មាធិការ និងត្រូវអនុម័ត ដោយការព្រមព្រៀងគ្នានៅក្នុងគណៈកម្មាធិការទាំងមូល

- សំណើធ្វើវិសោធនកម្មតួនាទី ភារកិច្ច និងរបៀបរបបការងារដោយសមាជិកម្នាក់ ឬច្រើននាក់ ត្រូវអនុវត្តតាមនីតិវិធី ដែលបានកំណត់

- បន្ទាប់ពីបានដាក់ចូលទៅក្នុងរបៀបវារៈ សំណើធ្វើវិសោធនកម្មនោះត្រូវពិភាក្សា និងអនុម័តក្នុងសម័យប្រជុំបន្ទាប់របស់គណៈកម្មាធិការ ។

ប្រការ២៤ .-

សមាជិកគ្រប់រូបនៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងារ លេខាធិការដ្ឋាន និងមន្ត្រីពាក់ព័ន្ធនានា ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៧

ជ.គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ប្រធាន

ស ខេង

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
- សមាជិក គ.ជ.វ.វ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ
លេខ ....០៤៩៧៧......./គ.ជ.ម.ម

[illegible]
ថ្ងៃទី១៩...ខែមីនា...ឆ្នាំ២០០៧

សេចក្តីសម្រេច
ស្តីពី
តួនាទី ភារកិច្ច និងរបៀបធ្វើការងាររបស់ក្រុមការងារ នៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៩៥ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមការងាររបស់ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- យោងតាមស្មារតីនៃអង្គប្រជុំរបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នាថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៦ ។

សម្រេច

ប្រការ១ .-

ក្រុមការងារនៃ គ.ជ.វ.វ មានភារកិច្ចសំខាន់ៗ ដូចខាងក្រោម ÷

- ធ្វើជាជំនួយការ និងផ្តល់យោបល់ដល់ គ.ជ.វ.វ និងអនុគណៈកម្មការនានារបស់ គ.ជ.វ.វ

- លើកសំណើជូន គ.ជ.វ.វ អំពីការរៀបចំបង្កើតអនុគណៈកម្មការនានារបស់ គ.ជ.វ.វ តាមតម្រូវការចាំបាច់ ព្រមទាំងសមាសភាព មុខងារ និងនីតិវិធីការងារសម្រាប់អនុគណៈកម្មការទាំងនេះ

- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ និងឯកសារដទៃទៀត រួមទាំងសេចក្តីព្រាងផែនការ និងថវិកា ដើម្បីដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេច

- ត្រួតពិនិត្យ និងធានាការអនុវត្តសេចក្ដីសម្រេចរបស់ គ.ជ.វ.វ ឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា
- ត្រួតពិនិត្យ និងចាត់ចែងសកម្មភាពរបស់ គ.ជ.វ.វ តាមការសម្រេចរបស់ គ.ជ.វ.វ នៅចន្លោះការប្រជុំរបស់ គ.ជ.វ.វ
- ផ្ដល់របាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនឱ្យបានទៀងទាត់ជូន គ.ជ.វ.វ និង
- បំពេញកិច្ចការទាំងអស់ដែលចាំបាច់ ដើម្បីធានាដល់ការប្រព្រឹត្តិទៅរបស់ គ.ជ.វ.វ ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ។

ប្រការ២ .-

ក្រុមការងារត្រូវទទួលខុសត្រូវ លើកិច្ចការជាអាទិភាព ដូចខាងក្រោម ÷

- ត្រូវដាក់ជូន គ.ជ.វ.វ ពិនិត្យ សម្រេចអំពីនីតិវិធី និងរបៀបរបបការងាររបស់ គ.ជ.វ.វ
- ដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចលើសេចក្ដីព្រាងក្របខ័ណ្ឌអនុវត្តបឋម ដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចលើសេចក្ដីព្រាងល័ក្ខខ័ណ្ឌការងារសម្រាប់ការរៀបចំតាក់តែងកម្មវិធីជាតិបឋម ដើម្បីការអភិវឌ្ឍបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ត្រូវរៀបចំ និងដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចលើសេចក្ដីព្រាងផែនការការងាររបស់ គ.ជ.វ.វ និងថវិកាសម្រាប់ឆ្លើយតបផែនការការងារនោះ សម្រាប់រយៈពេលនៅសល់នៃឆ្នាំ ២០០៦ និងឆ្នាំ ២០០៧
- ផ្ដល់អនុសាសន៍ជូន គ.ជ.វ.វ អំពីការបង្កើតអនុគណៈកម្មការនានារបស់ គ.ជ.វ.វ តាមការចាំបាច់ ។

ប្រការ៣ .-

ក្រុមការងារត្រូវជួយ គ.ជ.វ.វ ក្នុងការអនុវត្តនូវកិច្ចការដែលនៅសេសសល់របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ និងគណៈកម្មការអន្តរក្រសួងដើម្បីតាក់តែងសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ

ក្រុមការងារត្រូវប្រើប្រាស់មធ្យោបាយ និងដំណើរការចាំបាច់នានាដើម្បីធានាឱ្យគ.ជ.វ.វទទួល និងអនុវត្តមុខងារ និងភារកិច្ចខាងលើនេះឱ្យបានត្រឹមត្រូវ ។

ប្រការ៤ .-

ក្រុមការងារត្រូវចាត់ចែងអនុវត្តនូវផ្នែកទាំងអស់នៃក្របខ័ណ្ឌអនុវត្តបឋមដែលបានអនុម័ត ។

ប្រការ៥ .-

ក្នុងការរៀបចំកម្មវិធីជាតិបឋម ក្រុមការងារត្រូវចាត់ចែងការងារ ដូចខាងក្រោម ៖

- ស្នើរៀបចំឱ្យមានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល សមាជិកអន្តរជាតិ និងសមាជិកដទៃទៀតនៅក្នុងក្រុមរៀបចំបង្កើតកម្មវិធីជាតិជាបឋម
- ផ្តល់គោលការណ៍ណែនាំ ដឹកនាំ និងគាំទ្រដល់ក្រុមរៀបចំបង្កើតកម្មវិធីជាតិ
- ចាត់ចែងអនុវត្តផ្នែកទាំងអស់នៃកម្មវិធីជាតិបឋមដែលបានអនុម័ត ។

ប្រការ៦ .-

ក្នុងការរៀបចំមូលនិធិសម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ ក្រុមការងារត្រូវ ៖

- ដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចអំពីមូលនិធិពីដៃគូអភិវឌ្ឍន៍ សម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលបានស្នើសម្រាប់ដៃគូអភិវឌ្ឍន៍ ដែលមានបំណងប្រមូលធនធានរបស់ខ្លួន ដើម្បីគាំទ្រនៅថ្នាក់ជាតិ និងថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ទៅលើខ្លឹមសារ និងដំណើរការនៃមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ
- ក្រុមការងារត្រូវផ្តល់អនុសាសន៍ជូន គ.ជ.វ.វ ពីគោលនយោបាយ និងវិធីដ៏ប្រសើរបំផុតសម្រាប់ការចាត់ចែងមូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ
- នៅក្នុងអនុសាសន៍របស់ខ្លួន ក្រុមការងារត្រូវដាក់បញ្ចូលនូវការវាយតម្លៃអំពីតម្រូវការ និងការចង់ឱ្យមាននូវកិច្ចសន្យាជាមួយអ្នកចាត់ចែងមូលនិធិ រហូតដល់ពេលអាជ្ញាធរអនុវត្តន៍ដែលបង្កើតឡើងដោយច្បាប់រៀបចំអង្គការ ឬទីភ្នាក់ងារសមស្របមួយរបស់រាជរដ្ឋាភិបាលដែលមានសមត្ថភាពចាត់ចែងមូលនិធិទាំងនោះ ។

ប្រការ៧ .-

ក្នុងការប្រមែប្រមូលមូលនិធិនានា សម្រាប់វិមជ្ឈការ និងវិសហមជ្ឈការ ក្រុមការងារត្រូវ ៖

- ដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចអំពីជម្រើស យន្តការ ទីភ្នាក់ងារ និងការចាត់ចែងដ៏ប្រសើរបំផុតដើម្បីកៀរគរ និងចាត់ចែងមូលនិធិអន្តរជាតិសម្រាប់ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ត្រូវដាក់បញ្ចូលទៅក្នុងអនុសាសន៍របស់ខ្លួននូវ ជម្រើសយន្តការ ទីភ្នាក់ងារ និងការចាត់ចែងដ៏ប្រសើរបំផុតនៅមុន និងក្រោយការអនុម័តច្បាប់រៀបចំអង្គការ
- ត្រូវពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍នានាអំពីជម្រើស យន្តការ ទីភ្នាក់ងារ និងការចាត់ចែងដ៏ប្រសើរបំផុតនូវមូលនិធិរបស់ដៃគូអភិវឌ្ឍន៍

ប្រការ៨ .-

ក្នុងការរៀបចំ សម្រាប់ដំណាក់កាលអន្តរកាល និងការរំសាយកម្មវិធីសិលាជាបណ្តើរៗ ក្រុមការងារត្រូវ ÷

- ដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចពីយុទ្ធសាស្ត្រ និងដំណើរការដ៏សមស្រប សម្រាប់ដំណាក់កាលអន្តរកាល និងដំណាក់កាលរំសាយកម្មវិធីសិលាជាបណ្តើរៗ

- កំណត់អំពីមុខងារ និងការទទួលខុសត្រូវរបស់ក្រុមការងារកម្មវិធីសិលា និងលេខាធិការដ្ឋានកម្មវិធីសិលា ដែលផ្ទេរទៅឱ្យ គ.ជ.វ.វ ក្រុមការងារនៃគ.ជ.វ.វ ក្រសួងមហាផ្ទៃ ក្រសួង ស្ថាប័ននានា ឬទីភ្នាក់ងារជាតិ ឬទីភ្នាក់ងារនៅថ្នាក់ក្រោមជាតិនានា

- ធានាចំពោះការអនុវត្តយុទ្ធសាស្ត្រ និងដំណើរការដែលបានសម្រេចសម្រាប់ដំណាក់កាលអន្តរកាល និងដំណាក់កាលរំសាយកម្មវិធីសិលាជាបណ្តើរៗ ។

ប្រការ៩ .-

ក្រុមការងារត្រូវដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចលើសេចក្តីព្រាងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីការគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ ។

ប្រការ១០ .-

ក្រុមការងារត្រូវធានាឱ្យមានកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់នៅក្នុងចំណោមអ្នកពាក់ព័ន្ធនានា រួមមាន ÷

- ផ្តល់អនុសាសន៍ជូន គ.ជ.វ.វ អំពីការរៀបចំចាត់ចែងដ៏សមស្រប សម្រាប់ការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់រៀបចំអង្គការ និងក្របខ័ណ្ឌអនុវត្តបឋម

- សម្របសម្រួល និងធានាឱ្យមានការពិគ្រោះយោបល់ឱ្យបានគ្រប់គ្រាន់ ក្នុងចំណោមក្រសួង ស្ថាប័ននានា នៃរាជរដ្ឋាភិបាល ស្ថាប័នថ្នាក់ជាតិដទៃទៀត និងទីភ្នាក់ងាររាជរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ទាក់ទិនទៅនឹងការជ្រើសរើស ការផ្ទេរមុខងារ និងធនធានទៅឱ្យក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ

- គ.ជ.វ.វ ត្រូវធានាឱ្យមានកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់ដ៏សមស្រប និងគ្រប់គ្រាន់ រវាង គ.ជ.វ.វ ក្រសួង ស្ថាប័ន ទីភ្នាក់ងារនៅថ្នាក់ជាតិ និងទីភ្នាក់ងារនៅថ្នាក់ក្រោមជាតិ ។

ប្រការ១១ .-

ក្រុមការងារត្រូវធានាឱ្យមានវេទិកាសមស្របរវាងរាជរដ្ឋាភិបាល ទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាល ដែលរួមមាន ÷

- ផ្តល់អនុសាសន៍ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេចនូវការរៀបចំវេទិកាដ៏សមស្រប សម្រាប់ការពិគ្រោះយោបល់ ទំនាក់ទំនងកិច្ចសហប្រតិបត្តិការ និងការកៀរគរមូលនិធិរវាងរាជរដ្ឋាភិបាល ទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាល

- សម្របសម្រួល និងធានាឱ្យមានការប្រជុំសម្រាប់កិច្ចសហប្រតិបត្តិការរវាង គ.ជ.វ.វ ទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាលតាមការចាំបាច់

- ផ្តល់អនុសាសន៍ជូន គ.ជ.វ.វ និងចាត់វិធានការ ដើម្បីធានាឱ្យបានថា សកម្មភាព និងកម្មវិធីរបស់ទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាលនានា ស្របគ្នា និងស៊ីសង្វាក់គ្នាជាមួយក្របខ័ណ្ឌអនុវត្តបឋម និងកម្មវិធីជាតិបឋម ។

ប្រការ១២ .-

ដើម្បីធ្វើជាជំនួយការឱ្យ គ.ជ.វ.វអនុវត្តមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ក្រុមការងារមានសិទ្ធិ អំណាចដូចខាងក្រោម ÷

- អាចជួបប្រជុំជាមួយទីភ្នាក់ងារអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរាជរដ្ឋាភិបាលសម្រាប់ការពិគ្រោះយោបល់ ការផ្សព្វផ្សាយព័ត៌មាន ឬសម្រាប់គោលបំណងដទៃទៀតដែលស្ថិតនៅក្នុងការទទួលខុសត្រូវរបស់ គ.ជ.វ.វ

- រៀបចំសេចក្តីព្រាងច្បាប់ ព្រះរាជក្រឹត្យ ឬអនុក្រឹត្យដើម្បីដាក់ជូន គ.ជ.វ.វ ពិនិត្យ និងជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេច

- អាចស្នើសុំឱ្យក្រសួង ឬស្ថាប័នជាតិ ផ្តល់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងការអនុវត្តកម្មវិធីជាតិបឋម នៅក្នុងរយៈពេលកំណត់ជាក់លាក់មួយ

- អាចទទួលជំនួយបច្ចេកទេស ហិរញ្ញវត្ថុ និងសម្ភារពីប្រភពក្នុងប្រទេស និងក្រៅប្រទេស សម្រាប់គាំទ្រដល់ការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

- អាចជួលទីប្រឹក្សាជំនាញ ជាជនជាតិកម្ពុជា និងបរទេស តាមការចាំបាច់

-អាចចុះកិច្ចសន្យា រួមទាំងកិច្ចសន្យាទទួលជំនួយហិរញ្ញវត្ថុពីប្រភពក្នុងប្រទេស និងក្រៅប្រទេស និងកិច្ចសន្យាជួលទីប្រឹក្សាជំនាញ ស្របទៅតាមនីតិវិធីដែលបានកំណត់ ។

ប្រការ១៣ .-

ក្រុមការងារត្រូវជួបប្រជុំយ៉ាងហោចណាស់មួយខែម្តង

ក្រុមការងារអាចអញ្ជើញតំណាងក្រសួងផ្សេងៗទៀត ឬបុគ្គលទាំងឡាយឱ្យចូលរួមនៅក្នុងការប្រជុំរបស់ខ្លួនតាមការចាំបាច់ ។

ប្រការ១៤ .-

ក្រុមការងារត្រូវរាយការណ៍ពីសកម្មភាពរបស់ខ្លួន នៅគ្រប់អង្គប្រជុំរបស់ គ.ជ.វ.វ ។

ប្រការ១៥ .-

ក្រុមការងារត្រូវផ្តល់គោលការណ៍ណែនាំ និងការដឹកនាំដល់លេខាធិការដ្ឋាន គ.ជ.វ.វ

ក្រុមការងារអាចស្នើសុំជំនួយពីលេខាធិការដ្ឋាន គ.ជ.វ.វ សម្រាប់បញ្ហាទាំងឡាយណាដែលឋិតនៅក្នុងវិសាលភាពនៃភារកិច្ច និងអំណាចរបស់ខ្លួន ។

ប្រការ១៦ .-

សមាជិកគ្រប់រូបនៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងារ លេខាធិការដ្ឋាន និងមន្ត្រីពាក់ព័ន្ធនានា ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០០៧

ជ.គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
ប្រធាន

ស ខេង

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាល
- សមាជិក គ.ជ.វ.វ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៧៧ ពណ.នគក

ភ្នំពេញថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **រីម ប្រូភើធី អិលធីឌី**
REAM PROPERTIES LTD.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3309/06E ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៦
មានទម្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក CHARON JEAN-LOUIS " គតិយជន " ប្រធានក្រុមប្រឹក្សាភិបាល
លោក ETIENNE MICHEL CHENEVIER " គតិយជន " អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : សណ្ឋាគារ AMANJAYA PANCAM វិថីព្រះស៊ីសុវត្ថិ កែង ផ្លូវលេខ ១៥៤ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម
- ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណកម្មទំនិញគ្រប់ប្រភេទ នាំចូលឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គឹម_ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ០០៦៤ ពណ.នគក

ភ្នំពេញថ្ងៃទី ០៧ ខែមករា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **វិចតូរីយ៉ា.វ៉ាយ.អ៊ីន**
VICTORIA . Y . INC.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 9365/07P ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៧

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកជំទាវ **ឆាន ស្រីមុំ** ប្រធានក្រុមប្រឹក្សាភិបាល
លោក SOM NOM អភិបាល
លោកស្រី **អ៊ុយ ម៉ារ៉ែត** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិវត្ត សង្កាត់ប៉ៃលិន ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ គ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួលដឹកសំភារៈទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល.ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកក់រៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូនទំនិញចេញចូល

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

៩.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

គឹម ស៊ីថន

ចំលងជូន

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និង កីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាក្រុងប៉ៃលិន
- មន្ទីរពាណិជ្ជកម្មក្រុងប៉ៃលិន "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៦៨៦ ពណ.នគក

ភ្នំពេញ ថ្ងៃទី ០៧ ខែមករា ឆ្នាំ ២០០៧

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា ៖

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម ៖

១- នាមករណ៍របស់ក្រុមហ៊ុន : ណា ណុម ស៊ី អិន ស៊ី (ខេមបូឌា)
NANUM C N C (CAMBODIA) Co.,Ltd.

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3314/07E ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៧

មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក KO CHONG HYOK

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៣អឺ០ ផ្លូវលំ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ
-សាងសង់ ជួសជុល អាគារ ស្ពាន ផ្លូវ
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ច.ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
...ធិការ

គឹម_ស៊ីថន

<u>ចំលងជូន</u>

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ